" Roeung Sovannahong " R. 6-1-53

# រឿងសុវណ្ណហង្ស




RÉGIE
DÉPOT LÉGAL
B-3
D-82
N-2921
116

ឈ្មោះសៀវភៅដែលមានជាវនៅបណ្ណាគារ

# ជិង ង្វួន ហ្វួត

គឺ :

| | | | |
|---|---|---|---|
| ១– | ប្រស្នាវិនយបញ្ញត្តិ ទី ១ | ថ្លៃ | ៧៛០០ |
| ២– | បណាមគាថា | „ | ២៛០០ |
| ៣– | អវិជ្ជាកថា | „ | ២២៛០០ |
| ៤– | ភេសជ្ជក្ខន្ធកៈ ទី ៦ | „ | ២០៛០០ |
| ៥– | ប្រជុំពុទ្ធភាសិត ៤០០ បទ | „ | ៨៛០០ |
| ៦– | បុគ្គលកថា | „ | ៥៛០០ |
| ៧– | សន្ទនាត្រៃភាសា | „ | ១៥៛០០ |
| ៨– | សន្និសិទ សមាគមមិត្តសាលាបាលី | „ | ៥៛០០ |
| ៩– | ឃរាវាសធម៌ និង ច្បាប់ទូន្មានកូនចៅ | „ | ៥៛០០ |
| ១០– | សំវេគកថា | „ | ៤៛៥០ |
| ១១– | សុភាសិតសង្គ្រោះ | „ | ១៦៛០០ |
| ១២– | ពុទ្ធប្រវត្តិពាក្យកាព្យ | „ | ១៧៛០០ |
| ១៣– | សុន្ទរកថា | „ | ៦៛០០ |
| ១៤– | បញ្ហាសង្គម | „ | ១៤៛០០ |
| ១៥– | ប្រស្នាពុទ្ធសាសនា | „ | ៨៛០០ |
| ១៦– | ព្រះបាទជ័យវរ្ម័ន ទី ៧ | „ | ៥៛០០ |

1953 - 1
ល. 2



REGIE DU DEPOT LEGAL
ARCHIVES NATIONALES
COTE 82
B-114-1363

# សុវណ្ណហង្ស

(បទព្រហ្មគីតិ)

ខ្ញុំសូមលើកបទបាទ ដោយនិទានព្រះសាស្តា យោនយកព្រះជាតា
ជាវត្ថុលវិសេសសល់ ៗ មុននោះព្រះមហាក្សត្រ សោយសម្បត្តិ
គ្រង់វេហ៍ពល អនេកអនន្តសល់ ថ្កើងព្រះកេរ្តិ៍យសស័ក្តិសែង ៗ
ស្តេចមួយរយអង្គា ចូលវន្ទាក្សត្រគម្ពែង ថ្កើងព្រះយសស័ក្តិសែង
ដូចព្រះចន្ទពេញបូណ៌មី ៗ ព្រះនាមព្រះមហាក្សត្រ សុធនរាជាធិ-
បតី រុងរឿងបុទ្ធិរង្សី ត្រចះចែងចាំងវេហាស៍ ៗ ស្តេចមានព្រះ
មហេសី ឆោមពីសីសមសោភា ឈ្មោះកែវសុចិត្រា ជាធ្មើមអស់
ទាំងស្រីផង ៗ ស្រីកំគាល់ណាស់ណាន់ ណែនតាប់តាន់តំពេងទង
ថ្កើងយសស័ក្តិកន្ទង កន្ទែងលើសលើលោកា ៗ ស្តេចគង់ប្រាសាទ
មាស ថ្កើងឱភាសហាក់សួគ៌ា ស្រួតស្រួតដល់ពសុធា កំត្រចង់
ត្រចះថ្លា ៗ ប្រាសាទប្រសើរស្ងាប កំត្រចាចចែងវេហាស៍ ស្រោង
ស្រង់ស្រួចផ្កា យល់ត្រែដែតត្រដោមដុង ៗ ដាំត្បូងពេជ្រសូរ្យ
កាន្ត កែវពិតានលើដោមពុង រស្មីច្រះច្រាលប្រុង ប្រួចប្រលួច
ត្រឡេកត្រឡៅ ៗ បន្ទាយប្រាំពីរជាន់ ទាំងវិទត្រចំណ្ឆាយពេញរាំងក្រៅ
សឹងពេជ្រផលិចសន្ទៅ សន្ទោប្រះច្រាលល្អពេក ៗ អាមាត្យមុខមន្ត្រី
ពលសេនិយប្រើនអនេក គង់គាល់ស្តេចជាឯក អស់រាស្ត្រផងសុខ
សប្បាយ ៗ មហាក្សត្រមានអំណាច សេពសោយរាជ្យចុំថ្កើងថ្កុ

ឈប់ស្រុះសោយមទបរិ- បូណ៌សង្គ្រោះទើបថ្លែងពី ៗ បរមកដវង្គុល
ជាគម្ពីរពាន្សពោធិ៍ សត្វសោកសានបារមី ពុំទាន់ត្រាស់សម្ពុទ្ធ ៗ

## បទកាកគតិ

ទើបអគ្គទេវបុត្រ ទ្រង់ចាកចុត ចូលចាប់ព្រះជាតិ នៅនាឧទរ
មហាសីលស្អាត ទ្រង់នាមនាងនាថ កែវសុចិត្រា ៗ កាលនាងទ្រង់គភ៌
មានហេតុញាប់ញ័រ ប្រសើរក្រៃណា នាងនាថផ្ទំលក់ . សាន្តសុខ
និទ្រា លើខែនក្រលា បន្ទំរម្យរត័ន ៗ នាងទ្រង់ព្រះសុ-
បិនកាលនានៅ ក្នុងពេត្រស្ងាត់ ដូចបានទម្រង់ មាសផ្ទង់ពិចិត្រ ខព្វ
គុណវិមទាត លើបរស្មី ៗ ត្បូងកែវប្រះប្រាយ ភ្លឺផ្លេកធាធាយ
ប្រចប្រាលរង្សី សន្ធោសន្ធៅ ឆ្ពុះទៅទូទី ទិសទាំងប្រាំបី ដូចសែង
សុរិយា ៗ នាងអរសតផ្ទឹង ឥតថ្លែងនាទឹង ផ្ទឹមផ្ទាល់ឧបមា ក្សាន្ត
ក្សិណក្សត្រ ប្រិមប្រិយសោភា ភ្ញាក់ភ្ញាក់និទ្រា ដៃដោយពុំយល់ ៗ
នាងដឹងជាអញ្ញ ដេកលក់អម្ញិញ យល់សប្តិសោះសល់ សប្តិគាថ្ម
ទេ គួរឲ្យអញធ្ងល់ ពុំដែលយង់យល់ នាងចាំនិត្យនៅ ៗ លុះ
ព្រឹកភ្លឺស្រាង សុរិយាបំព្រាង រឿងរះផ្អិនផ្អៅ សូរ្យសែងពេញពាល
ប្រចប្រាលសន្ធៅ សន្ធានិត្យនៅ ទិសទីបូព៌ាបាន ៗ នាងសោយព្រះ
ស្ងួន បរិបូណ៌ស្រីគន់ ស្រីតួចកល្យាណ ក្រួញក្រាបសិរសិត ជួញ
ជិតប្រែបប្រាណ ទើបទូលក្សត្រក្សាន្ត តម្លួងក្រលា ៗ បពិត្រព្រះ
បាទ ព្រះបរមនរនាថ ឥស្សរសិរសា ខ្ញុំយល់និមិត្ត ពេញពិតក្នុង-

សាធារណរដ្ឋប្រជាមានិតកម្ពុជា
បណ្ណាល័យជាតិ
លេខបញ្ជី:

ត្រេត្រែកចិន្តា ដាលដោយសព្វសព៌ ហាក់បានទម្រង់ ត្បូង
កែវរត្នផង់ ល្អឥតផ្ទឹមដល់ រុងរឿងបវរ គង់ព្រះមណ្ឌល ឆ្លាស់ឆ្លុះ
យង់យល់ តាំងទិសប្រាំបី ។ ភ្លឺផ្លេកប្រែពត់ ព្រោងព្រាយនូវរត្ន
វិជរង្សី ខ្ញុំភ្ញាក់ឡើងប្លាត់ អរក្តាតពេកក្រៃ តែខ្ញុំសង្ស័យ ពុំដឹង
កាចជា ។ ស្ដេចស្ដាប់ទេវី ទូលអស់សេចក្ដី សព្វសោះប្រុះប្រា-
កដក្ទួមហាក្សត្រ អរក្តាតត្រាស់ថា សព្វនាងនេះណា ត្រកាលក្រ
ក្រៃ ។ ស្រេចក្សត្រនរនាថ ត្រាស់ប្រើអាមាត្យ រុះរត់ប្រៀវប្រែ
ទៅហៅហោរា ក្សត្រាឈ្មោងវៃ អាមាត្យសោតថៃ រួសរាន់រត់ទៅ ។
ហៅហោរាមកដល់ ឡើងលើមណ្ឌល ពេញរត្នឥតសៅ ឯអង្គព្រះ
បាទ នរនាថចមចៅ បើកបន្ទូលទៅ ប្រាយប្រាប់ហោរា ។ ហៃ
ហោរចូរស្ដាប់ អញនឹងថ្លែងប្រាប់ សុបិននាងណា នាងយល់ហាក់
បាន សូរ្យកាន្តកែវជា ដាំសុវណ្ណា ទម្រង់រត្នរាយ ។ ភ្លឺផ្លេក
សាយសល់ ចុះឆ្លាស់យង់យល់ នូវទៅទីឆ្ងាយ តាំងទិសប្រាំបី រស្មី
ព្រោងព្រាយ សព្វបច្ចុំទំនាយ ដំណើរជាម្ដេច ? ។ ហោរស្ដាប់ព្រះប-
ន្ទូលទើបហោរគុណា ហាហើយស្រាប់ស្រេច យល់យល់អស់បូពិ
ទើបទូលសម្ដេច សំដែងដោយក្ដី ដោយគលសាស្ត្រា ។ បពិត្រព្រះ
បាទ ព្រះបរមនរនាថ ឥស្សរសិរសា និមិត្តខ្ញុំមើល ប្រសើរថ្លៃថ្លា
តាមដោយតម្រា គំនូរទៀងតាយ ។ ជាពង្សទេពី នឹងទ្រង់គភ៌-
សេសសុទ្ធពណ្ណរាយ រតនរាជទិរស ប្រាណប្រះគបកាយ វង្សពុទ្ធិ

ប្រាជ្ញប្រាយ លើសលើលោកា ។ ស្តេចស្តាប់ហោរទូល ព្រះបាទ
ឥស្សូរ ត្រីត្រូវត្រៃកសរ ស្តេចឲ្យរង្វាន់ ហោរគ្រាន់បវរ មាសប្រាក់
ដុំមិពារ ទិព្វបានបូជា ។ ក្រោយនោះទៀងវែត លុះគភិគ្រប់ខែ
ឈើវែថ្ម សោះសា ទៀងទើបឆ្លោះធ្លាក់ ចេញចាកឧទរា រ័តន៍រាជមាតា
ប្រសើរសល់ស្រី ។ ហេតុទេពឲ្យត លួលះប្រាកដ កាយគល្យាណី
ដូចមាសនព្វគុណ ទិព្វតន់ស្មើ ភ្ញីផ្កាកដូចទី មិត្តមិនឃ្លាតឃ្លា ។
ព្រះបាទមហាក្សត្រ ចមះចាប់ក្រវត្តិ បិតាមាតា បេតអំណរ ត្រេក
អរក្តាក់ណា សន្មតនាមា រ័តនរាជកុមារ ។ ហេតុព្រឹក្ស ពន្លក
បណ្តូល លួលះត្រកាល ឈ្មោះសុវណ្ណហង្ស ទ្រេសទ្រង់សម្ភារ
រស្មីក្រហល លួករះពេកពិត ។ ព្រះបាទឧត្តម ឲ្យរើសមេដំ
បំបៅផ្ដុកផ្គត បីត្រងពលៀង ច្បបច្បៀងស្រណោក បន្ទន់បុត្រត្នូ
ឥតឲ្យមានហ្មង ។ កាលព្រះចូលដុំ បម្រើងស្ងួតសម បំពេចាំនៅ
ច្បបច្បៀងផល្ពាយ អស់ដោយក្សេនទៅ សរសើរចមះនៅ ផ្ទាស់
ផ្ទើយគាន់គ្នា ។ លុះព្រះធំហើយ បៀងប្រចផ្ទាស់ផ្ទើយ ស្ងួរ
វែសថ្ងៃថ្ងៃថ្នា ដំណាលដំណើរ សរសើរពណ៌នា បុណ្យបារមីតា
ប្រក្រតីសព្វថ្ងៃ ។ បិតាអនុគ្រល បុត្ររ័តន៍បណ្តូល បណ្តាច់ហប្
ច័យ ស្នេហាសន្ទគ្រង ឥតហ្មង់ឡើយនៃ រូបរាងប្រពៃ បានសោឡ
សា ។ ស្តេចរៀបអភិសេក រាជបុត្រជាឯក សេពសោយរាជ
អស់ស្តេចមួយរយ រវេយនាំគ្នា គប់គ្រឿងបូជា ថ្វាយព្រះដៀស្ង័យ ។

សេនាមន្ត្រី ផងច្រើនពេកក្រៃ ព្រាហ្មណ៍ព្រឹទ្ធករី គង់គាល់
ព្រះបាទ នរនាថនរបតី ស្ដែងស្ដេចផាត់- ស្បូវគ្រងភព ។
ក្សេមក្សាន្តសុកល ពុំបានអំពល់ អំពើទុក្ខា ប្រកបបារមី
ពោធិសត្វា អស់ក្រស្ដប្រជា សឹងសុខសប្បាយ ។ រីវិមាននេះ
សណ្ឋិតទុកស្មេះ ហើយនឹងនិយាយ មានកផុរី ដទៃគ្នាឆ្ងាយ
ក្សត្រយក្សឫទ្ធិសាយ គ្រប់គ្រងភព ។

## បទពំនោល

រីនាមនគរនោះណា មោះតាំងត្រាមា បុរីបរមពផស្ថាន ។ ក្សត្រ
យក្សឫទ្ធិសក្តិសម សោយរាជ្យឧត្តម ឧត្តុង្គថ្កើងយសសក្តា ។ ឈ្មោះ
ក្រុងបាទបិត្រា ឥស្សូរយក្សា ខ្ញុបខ្ញាចបំណាចរិទ្ធី ។ រីឯព្រះរាជទេពី
នាងក្ស័យធរី នៅតែព្រះរាជបុត្រី ។ ទ្រង់ឆោមឆាយាល្អក្រៃ ដូចចន្ទ
បូណ៌មី ត្រចះត្រចង់ចើតឆាយ ។ ឈ្មោះកេតសុរិយង់ពណ្ណរាយ រូប
ទេពស្នួគិនាយ នឹងផ្ទឹមឲ្យត្រឹមពុំបាន ។ ព្រះវរបិតាប្រទាន រក្សាបុត្រ
បាន រុងរូបបញ្ចុសរសុវា ។ ស្ដេចឲ្យប្រដាប់ប្រដា ប្រាសាទសោភា
រចនាស៊ឹងមាសឥតសៅ ។ ហើយឲ្យនាងនាថស្រីពៅ នាងគង់និត្យនៅ
ទីទៃពីព្រះបិតា ។ ស្ដេចឲ្យកំលៀងរក្សា ប្រាំនាក់សឹងជា គំនាប់
គំនួនសួនសម ។ សឹងស្រីប្រិមប្រិយឧត្តម ជាប្សង់អស់ស្នំ បំរើត្ថ
រាជកញ្ញា ។ នាងគង់ក្សេមក្សាន្តទយា ហេតុបុណ្យប្រុង្វា ជាយានឹង
ព្រះសុវណ្ណហង្ស ។ មួយថ្ងៃស្រីរត្នវង្ស ពុំសុខសាន្តក្តុង ព្រះទ័យ

ចង់ចរលេណា ។ ប្រពាតព្រៃព្រឹក្សា ស្រង់ព្រះគន្ធា ក្រសាល
លំហើយព្រះអង្គ ។ គិតស្រេចស្រីថ្ងៃវង្ស ទ្រង់គ្រឿងបញ្ចង់ ឡើង
គាល់ព្រះវរបិតា ។ ស្រីថ្ងៃប្រពៃសោភា ដល់ស្រេចវន្ទា បង្គំប្រណម្យ
ថ្វាថ្ងៃង។ ក្រាបលាយាត្រាទៅលេង នាងគង់ដោយល្បែង ក្នុងសួនឧទ្យាន
ព្រឹក្សាព្រៃ។ ក្រសាលលំហើយហឫទ័យ ស្រេចខំវិលវៃ វិលមកពុំលង់
យូរឡើយ ។ បិតាស្តាប់បុត្រទូលហើយ ក្សត្រាត្រានត្រើយ ស្តេច
ព្រមព្រម័យសាទរ ។ ពុំហាមទាំងឃាត់ឲ្យបរ លេងឆ្នេរសាគរ កំ-
សាន្តតាមចិត្តចិន្តា ។ ស្តេចមានបន្ទូលត្រាស់ថា ហៃកូនស្ងួនភ្ងា ទៅ
ហើយកុំផ្សង់យូរឡើយ។ រសៀលព្រះសុរិយាហើយ ចូរវិលកុំផ្សាយ កុំ
ផ្សង់ឲ្យយូរឡើងនៃ ។ នាងស្តាប់សាសព្ទព្រះបិ- តាទើបក្សត្រី បង្គំ
ប្រណម្យលុតលា ។ មកដល់ប្រាសាទជយា ក្សត្រីសោភា មាន
ព្រះបន្ទូលសាស័ង ។ ថាហៃភិលៀងអើយបង ប្រាប់មន្ត្រីផង ឲ្យ
រៀបរាជរថសារថី ។ ជ្រិតអញចរចេញលេងព្រៃ ប្រពាតដលស័យ
កំសាន្តក្នុងចិត្តចិន្តា ។ ឲ្យរៀបពលផងស្រុះភ្នា ព្រឹកឡើងយាត្រា
ប្រពាតព្រះព្រៃឧទ្យាន ។ សេនាស្តាប់ហើយឃ្មាតខ្មី ប្រាយប្រាប់
សេនីយ ដោយឡែកដោយទីទៃ ។ រៀបស្រេចចូលទូលស្រីថ្ងៃ
ប្រាបហើយវៃ។ ទ្រង់គ្រឿងអាភរព្រះសុរង ។ ពាក់មកុដរត្ន
ក្ការកកង ល្អសលាយទៃទទង រំលងរំលេចឆ្កៅឆ្កាក់ ។ ព្រះ
ពស្ត្រក្សាប៉ាទប៉ាក់ ដដោយសមសក្តិ ទម្រង់ពាក់ព្រះហស្តថ្ងៃ ។

ទ្រង់គ្រឿងរុងរឿងប្រពៃ ល្ហលាល្ហមល្ហៃ ល្អៀងគង់រត្នកែវសុរ្យកាន្ត ។

## បទភុជង្គលីលា

កដរថមកិតរូបហាន កង់កាំកែវមាន ពេជ្រពាសផ្លាស់ធ្នុះ ។ ក្បូរក្បាច់រលេចសាយសុះ សឹងកែវក្លឹប្រុះ ក្លឹផ្ទុកច្រេះច្រាល ។ កញ្ចួងកញ្ចកផាំផាល ផ្លាស់ពេជ្រពពាល រត្នរឿងរង្គា ។ ហាក់ឋានសួគ៌ត្រៃត្រឹង្សា ស្រូតស្រុតមកនា ពិភពផែនដី ។ កិលៀងតាំងព្រាំប្រិមប្រិយ អស់ស្នំសៅស្រី ហែពជាយា ។ អស់ពលសុកលយោធា ហែហមគ្រៀបគ្រា ដោយខ្សែកទៃទី ។ អឹងកង់ទ្រហឹងប្រថពី ស្រេចដល់ទួលទី ឧទ្យានតុលង់ ។ ក្សត្រប្រពៃវវង្ស ព្រាមព្រាប់អស់អង្គ ពលពាលសេនិយ ។ ឲ្យឈប់ក្រោមម្លប់ព្រឹក្សព្រៃ សេនាផងវៃ ព្រាមព្រាប់ទៅពល ។ កុំមានខ្ទីខ្ទានរវល់ព្រាមព្រាប់រវល់ ដោយមេដោយនាយ ។ ពោះទ័ពសូរសព្ទឆ្ងាយអឹងអាប់សព្ទសាយ ក្នុងព្រៃឧទ្យាន ។ គយឃ្មុំចាំមាត់ហាន ប្រ-យ័ត្នកែកងមាន សត្រូវផ្ទុមផ្ទុន ។ ស្រីថ្ងៃប្រពៃរួសរាន់ ចុះពីសុវណ្ណ នាំអស់ស្រីផង ។ លេលាយាត្រាតែញ៉ងញ៉ង បរិពារត្រសង ហែនាងជយា ។ បេះផ្កាម្លិះរុតម្លិះលា កវកាកណ្ណិកា និលុប្បលរត្តុ-ប្បល ។ ចំប៉ីទួនស្រីចង្កុល- ណីទូវផ្កាផ្កុល រំដួលក្តាំងងារ ។ នាងបេះបានក្រាលក្រងជា បក្សីបក្សា ប្រចាប់ទងក្លី ។ ជារូបកិន្នរកិន្នរី ស្រស់ស្រេចប្រិមប្រិយ រកំល្អកែ ។ រំលេចក្បូរក្បាច់ស្រី

ថ្ងៃ ចន្ទផ្គួតកេសី ក្រសាលសប្បាយ ៗ ស្រីផងអឹងកងរ្ពសពយ ស្រើបស្រួលសប្បាយ លោតលេងក្នាល់គ្នា ៗ ខ្លះរត់បរផុតវេក ខ្លះចាប់ប្រាក់ បំចាប់គ្នាលេង ៗ ខ្លះរត់ខ្លះដេញជាល្បែង វិលវេះប្រ-ល្បែង ប្រឡងដេញផិត ៗ ស្រីថ្ងៃប្រពៃស្នេហ៍ស្និទ្ធ សប្បាយពេកក្កាត់ បបួលអស់គ្នា ៗ ចុះស្រង់កំពង់ជលសា ហើយនាងជយាផ្លាស់ពស្ត្រអស់ផង ៗ ចុះស្រង់ក្នុងជលអឹងកង ហិចហែលប្រឡងប្រជែងសប្បាយ ៗ គរញ្ញាកករញ្ញើរគ្គាកគ្គាយ អឹងកាប់សប្បាយហែលហក់ទៅមក ៗ នាងកេតសុរិយងំពន្ទក ព្រះទ័យនឹកក្នុកក្នុងព្រះចិន្តា ៗ ស្រេចនាងយកកម្រងផ្កា អធិដ្ឋានថា រកពជស្វាមី ៗ បើក្សត្រណា មានបុទ្ធី ជាគូពិតពី ព្រេងព្រេងប្រាកដ ៗ សូមឲ្យអស់អង្គទេវបុត្រ នាំផ្កាបរិសុទ្ធ ដម្រង់ក្សត្រនោះ ៗ ឲ្យស្តេចចរ-ចេញចំពោះ ដល់ហានខ្ញុំស្មោះ ឥឡូវនេះនៃ ៗ ផ្សងស្រេចសម្តេចក្សត្រី យកផ្កាក្រងថ្មី ដាក់ក្នុងគង្គា ៗ ហេតុបុណ្យស្រីគន់ពុំរ៉ា នឹងព្រះកជា នាមសុវណ្ណហង្ស ៗ ទេវតានៅនាស្រះស្រង់ ដឹងហេតុនាងទ្រង់ សច្ចាប្រណិធាន ៗ ប្រាប់ក្នុងព្រះទ័យមៃនមាន នាងគូបុព្វណា នឹងព្រះសុវណ្ណហង្ស ៗ បើញោះគួរអញនាំត្រង់ នគរព្រះអង្គ ជាតិជាស្វាមី ៗ និពានពីរក្សត្រផ្សងស្រេចហើយនៃ ឡើងពីគង្គា ៗ ទ្រង់គ្រឿងរុងរឿងថ្ងៃថ្លា ឡើងគង់រថា វិលវិនបុរី ៗ ដល់ស្រេចសម្តេចក្សត្រ

ថ្វាយវៃទ្ធី ព្រះវរបិតា ។ ស្ដេចយល់បុត្រដល់ហើយណា ព្រះវរបិតា ស្ដេចត្រេកអរសល់ ។

## បទភាកគតិ

ព្រះបាទចិត្រា បន្ទូលត្រាស់ថា ហៃកូនទិមិល ចូរនាង លេលា ប្រាង្គប្រាសាទស្កល់ ដ្បិតកូនមកដល់ នឿយព្រួយចិន្ដា ។ កុំគាល់យូរលង់ នឿយព្រួយហត់អង្គ កូនកែវពុំងា កាលណោះ ក្សត្រី ប្រិមប្រិយត្រាបណា វិលវឹងប្រាង្គប្រា- សាទសួគ៌មនោរម្យ ។ ផ្លាស់ពរពស្ត្រា ស្រេចស្រង់គង្គា ក្សេមក្សាន្តសុខសម សោយ ភោជនា ពីសាឧត្តម សប្បាយឥតគំ ពល់តើទុក្ខា ។ រីទិវាន នេះ យើងឈប់ទុកស្ទេះ ហើយនឹងចាប់ ពិតពីព្រះសុ- វណ្ណហុងថ្ងៃថ្វា ស្ដេចគង់នៅនា ប្រាង្គប្រាសាទរ័ត្ន ។ ជា ហេតុបែជន់ ថ្ងៃនោះគិតគន់ ចរចេញទៅថ្វាត់ ស្រង់ព្រះ- គង្គា ក្សត្រាបត្រៃត្តិ បើកព្រះឧស្សូរ័ត្ន ថាហៃអាចារ្យ ។ ព្រះស្ដេចនឹងឃ្លាត រួតរត់សង្វាត ប្រាប់អស់សេនា ឲ្យរៀបបរពល សុកលយោធា រាជរថរថា រួសរាន់វៃ ៗ ។ ដ្បិតអញនឹងចរ ចេញចាកនគរ ទៅលេងព្រីក្សព្រៃ ស្រង់ព្រះគង្គា ដលសា នាថ្ងៃ នេះចូរឆាប់វៃ វិលមកម្ចីមា ។ អាមាត្យស្ដេង ស្ដាប់ រួសរត់ប្រញាប់ ស្រែកហៅសេនា ឲ្យរៀបរាជរថ ប្រាកដរួសរា ដ្បិតស្ដេចលេលា ប្រពាតដលស័យ ។ ក្សណា

អស់សេនា ស្តាប់សព្វវាចា រៀបរថសារថី មុខមន្ត្រីត្រៀប
ភាយរៀបឆាប់ខ្ចី ពលពាលសេនីយ សេនាគ្រប់គ្រាន់ ៗ គ្រប់
គ្រឿងសស្ត្រា ស្រេចចូលវន្ទា ក្សត្រថ្ងៃសោភ័ណ ស្តេចជ្រាបម្មីម្មា
យាត្រាស្រួភាន់ ស្រន់ស្រេចទ្រង់គន ដរសេជ្រះថ្វា ៗ ទ្រង់ព្រះ
ពស្ត្រមាស រុងរឿងទិកាស មកុដកែវរចនា សង្វាកង់កន់
ទិព្វគន់សោភា សុភាពឋាក់ផា ទិព្វទេពបុត្រ ៗ ស្រេចស្តេច
លេលា គង់ភផថា កែមកែវបរិសុទ្ធ កង់កាំមុក្តា មហាមកិត
ពេជ្រពីដីរ័ត៌ កែមកែវស្សុរ្យកាន្ត ៗ ប្រែកទុបប្រែកបាំង ញ្ញ
ឈ្នាន់បល្ល័ង្ក បន្ទោលមាសមាន ត្បូងពេជ្រដាំផាស់ ធ្ងះផ្លាស់ប្រពាន
ទិលនៃបរូហាន ហាន់តែត្រីង្រា ៗ

## បទភុជង្គលីលា

រថរ័តន៍ប្រាក់ជ្រះថ្វា បល្ល័ង្កផ្ចិតផ្ចង់ រូបគ្រុឌទ្រទ្រង់ ៗ កញ្ចាង
កញ្ចាកយល់យង់ សឹងមាសបញ្ចាង បញ្ចារ័តន៍រាយ ៗ ត្រែសូល់កំ
ពួលគាំងឃ្មាយ ដាស់ដាំពិណាយ ពិទ្យស្សូរ្យកាន្ត ៗ បុស្សរថប្រាក់
មែនមាន រស្មីលលាន ភ្លឺផ្លេកវេហាស៍ ៗ អស់ពលសុភលយោធា
វៃហ ៗ ក្សត្រា ស្រេចផល់ផលធី ៗ ស្តេចផ្លាស់ពរពស្ត្រាខ្ចី ព្រះ
បាទនរបតី នាំអស់ស្រីផង ៗ អភិយាយសប្បាយកន្ទង់ ស្រីការ
សោភសោភង់ ហាំចហែលក្នាល់គ្នា ៗ កញ្ញាកញ្ញាកផលសា មុជ
ចាប់ដើងគ្នា ស្រៀវស្រែកសាទរ ៗ អឺអឹងទ្រហឹងខ្វាយខ្វះ ព្រះបាទ

កុញ្ជរ ស្ដេចស្រង់គង្គា ៗ ក្បែរណាឯកម្រង់មាលា ដែលនាងជាយា អធិដ្ឋានផ្សង ៗ សាត់ត្រង់ដម្រង់ក្បែរតែបង្វែង ដូចគេពាក់កង ទូវព្រះ ហត្ថា ៗ ស្ដេចឱបក្រសោបមាលា ទើបថ្លៃត្រាស់ថា បើផ្កាសព្វ ដង ៗ ក្រអូបផោយកលទេហោង ផ្កានេះមាសបង បំភ្លេកក្ដាត់ ណា ៗ ធុំក្លិនស្រិតទុំផា ចូលដង់ក្លិនផ្កា ល្ងង់ល្ងើយពេកសល់ៗ ស្ដេចថាឱ! ផ្កាទិមិល ប្អូនប្រើមកដល់ បងបានដឹងជាក់ ៗ ផ្កាអើយ ប្អូនមាសវរលក្ខណ៍ នៅទីសំណាក់ ដម្បូនឋានណា ៗ ផ្កាប្រាយ ប្រាប់មកឆាប់ក៏ ឲ្យដឹងទិសា ទិសទីប្អូនពៅ ៗ បងនឹងលេលាតាម ទៅ ឲ្យដល់លំនៅ ប្អូនមាសស្នេហ៍ស្និទ្ធ ៗ ស្ដេចឱបក្រសោប ផ្ទួញផិត ពិលៀបពេកក្ដាត់ ទួញទល់ទុក្ខា ៗ ស្រីប្អូនមាសនៅឯ ណា ពុំយល់កក្ដ្រា ប្រើតែផ្កាមក ៗ តាងមេមាសស្នេហ៍ពន្លក ប្អូន បាត់ទឹងរេក រេកមាសពុំយល់ ៗ ស្ដេចឱបក្រសោបបូរផល ឡើងពី កុងផល ផុស់ពរពស្ដ្រា ៗ ឡើងគង់រាជរថលេលា មន្ត្រីយោធា ហែ ៗ ក្សត្រថ្ងៃ ៗ ពលផងអឹងកងក្រាស់ក្រៃ ហែក្សត្រដល់ឮ រ័តទ៍ រាជសេមា ៗ ស្ដេចឱបប្រសោបបុប្ផា ឡើងលើប្រាង្គប្រា សាទ មាសបវរ ៗ

## បទភាកគតិ

ព្រះពោធិសត្វ ពន្លកបរមត្ថ ស្ដែងស្ដេចចេញចរ ដល់ព្រៃបន្ទំ សួរ សមកុញ្ជរ ព្រះហស្ដគក់ ទឹកទួញយំ ៗ ឱបគ្រឿងមាលា

សែនសោយសោកា ជាប្អូនឧត្តម នាងនៅឯណា ក្រងផ្កាស្លឹក
សម ល្អល្អះពេកក្តុំ មានកេយកេសរ ។ ឱ! ក្លិនមាសបង ចូល
ជាមួយផង ក្លិនក្លែបបរ ក្រអូបឈួយឈ្ងប់ សាយសព្វអស់បរ
មណ្ឌលខ្ចាយខ្ចរ ពិតពុំសង្កា ។ ឱ! ប្អូនមាសមិត្ត ឃាកប្អូននៅ
និត្យ ទៀបទេក្លូវណា ផ្កាក្រងថ្មី ៗ ប្អូនស្រីពុំងា ជាក់ដោយគន្ធា
ប្រើមកដល់បង ។ បងពុំដឹងតែ ជាប្អូនមាសស្នេហ៍ មាសមិត្តទំនង
នៅនាត្រង់ណា ប្រើផ្កាកម្រង បំពាក់ដៃបង បងបានដឹងជាក់ ។
បើប្អូនពុំងា នៅឯមនុស្សា ឬប្អូនវិលក្ខណ៍ នៅដល់តុសិត ឋាន
បិតស្លូតសាក់ ឬនៅសំណាក់ ពិភពនាគា ។ បើដឹងជាក់ហើយ បង
ពុំលង់ឡើយ តាមមាសស្ងួនភ្ងា ឲ្យយល់ព្រះភក្ត្រ គ្រាអ្នកកាលគ្រា
នេះនឹងលេលា យកប្អូនឲ្យបាន ។ ឥឡូវស្ងួនស្ងុំ ពុំដឹងដើមចុង
ប្ដេះគិតឲ្យក្រាន្ត ឲ្យក្រាន្តចិន្តា ត្រង់ណាទើបបាន ផ្ដាំឲ្យផ្កាប្ពាន
ប្រាយប្រាប់បងក៏ ។ ស្ដេចសែនសោយសោក សោកសល់អាមោក
ញ័ររកអស់អង្គា ប្រះប្រាណសន្ធប់ ស្ងួនសព្វនៅនា កម្រងមាលា
បាត់បង់ស្មារតី ។ អស់សុំស្រីង្គា បំរើជាស់ជា យល់ព្រះភូមិ ប្រះ
ប្រាណសន្ធប់ ស្ងួននៅទីងទី កាំងកិតឥតបី ផ្សេងផ្សើមឧបមា ។
ខ្ទះចូលជិតខាង ខ្ទះរត់បំព្រាង បំព្រំហាត់ហា ចូលទូលព្រះបាទ នរ
នាថថ្លៃថ្លា ជាព្រះបិតា មាតាស្ងួនគ្រង ។ បពិត្រសូមទាន រាជ
បុត្រក្សត្រក្រាន្ត សោយសោកកន្ទង សន្ធប់ស្ងួនស្ងាត់ បង់បាត់សាសង

ពុំដឹងទំនង ដំណើរម្តេចម្តា ៗ ស្តេចស្តាប់ស្រីឆ្គាំ ទូលប្រាប់ក្លាក់ក្លា:
កិតភ័យតក្កមា តាំងព្រះជននី ឃ្លាតខ្លីយាត្រា សុះរត់ម៉ឌ្ឍា ដល់ប្រាសាទ
រ័ត្នៗ ចូលដល់ហើយណា នុចបុត្រីសង្ក្រា ទើបថៃសិរសិត យកព្រះគង្គា
ថ្វាជ្រះបរិសុទ្ធ លប់ព្រះកត្តៃក្រែត ព្រះរាជបុត្រា ៗ ស្ដេចមានស្មា-
រតី ឱនអង្គមូលី បិតាមាតា ស្ដេចអរឱនឱប ក្រសោបបុត្រា ល្អូង
លោមស្នូរថា ហៃបុត្រប្រិមប្រិយ ៗ មានហេតុកលកិច្ច ដំណើរ
កលម្តេច កាលកូនមាសថ្លៃ ចេញទៅព្រៃពាត មានហេតុអ្វីនៃ ទើប
កូនពិសី សែនសោយសោកា ៗ ចូរប្រាថ្លែងប្រាប់ យើងនឹងស្ដែង
ស្ដាប់ ឥឡូវនេះណា សោះយើងកិតភ័យ ព្រួយចិត្តចិន្តា ម្តុមួយ
សូនក្បា ឈឺចាប់ក្នុងអង្គ ៗ ពោធរង្គូល ស្ដែងស្ដាប់បន្ទូល បិតា
ស្ដេចទ្រង់ កិតតក្កកម្មា ក្សត្រាវរវង្ស ទូលក្សត្រីវរពង្ស ដូច
ដោយសម័យ ៗ បពិត្រក្សត្រក្រុន្ត កាលខ្ញុំចរប្កាន ទៅលេងដល
ស័យ មានផ្កាសាត់ព្រាស់ ក្រលះវិលវៃ ទឹកទើបចូលដៃ ខ្ញុំក្នុង
គង្គា ៗ ផ្កាក្រង់ល្អពេក ល្អពន់ចំឡែក ចំលាក់របនា ធុំក្លិន
ស្រី ប្រិមប្រិយសោភា ចូលផង់ក្លិនផ្កា ក្រអូបពុំបាត់ ៗ ផ្កានេះ
ស្រីតន់ នាងផ្សងដោយបុណ្យ មកដល់ខ្ញុំប្ញាត់ ផាគូកំណាន់ ពី
ព្រេងទៀងទាត់ ទើបផ្កាបុប្ផរ័ត្ន័ សាត់ចូលដៃខ្ញុំ ៗ បិតាមាតា
ស្ដាប់បុត្រទូលថា ប្រាប់សព្វដោយដំ ណើរនៃបុត្រទូល ដោយ
បូតិពីអំ ពីចន្ទ្រនបទុម សែនសោយសោកា ៗ បិតាអនុកូល

ស្តាប់បុត្រទៀនទូល ស្រេចហើយក្សត្រា បែរបើកព្រះសូរ បន្ទូល
ត្រាស់ថា កូនអើយកុំបា គន់គិតសោយសោក ៗ អាពុកជួយគិត
កុំបាព្រួយចិត្ត សែនសល់អាះមាក ឲ្យកូនក្សាន្តចិត្ត គន់គិតរិះរក
គលកិច្ចឲ្យយក ជាងមកធ្វើខ្លែង ៗ ស្រេចកូនប្រឹមប្រិយ ផ្សង
បុណ្យបារមី ឲ្យយល់ជាក់ស្តែង បើប្រាកដជា គូបាពីព្រេង ទេព
តានាំខ្លែង ជូនដល់ឋានណោះ ៗ ពោធិសត្វា ស្តាប់ព្រះបិតា ផែង
ជួយឧត្រោះ ព្រួយព្រះហឫទ័យ ក្សត្រថ្ងៃស្ពានស្មោះ បន្ធូរសោក
សោះ តាមព្រះបិតា ៗ ទើបបើកបន្ទូល ព្រះឥស្សមត្បូ ត្រាស់ប្រើ
អាចារ្យ ឲ្យហៅជាងខ្លែង ព្រះស្តែងមីមា រួសរត់យាត្រា ឆាប់ដៃ
ពុំលង់ ៗ អាមាត្យស្តែងស្តាប់ ត្រាស់ប្រើប្រញាប់ ពិតពុំផ្សូរផ្សង
រួសរត់លលេញ ឃ្លាតខ្ញេញដម្រង់ ផ្ទះជាងពុំលង់ ស្រែកហៅមីមា ៗ
ហៃជាងចូរឆាប់ រួសរៀបប្រដាប់ ឡើងគាល់រួសរ៉ា ជាងស្តាប់អា
មាត្យ ខ្ញុំឃ្លាតយាត្រា រត់តាមអាចារ្យ ស្រេចដល់ពេងវ្យ - ៗ
ស្តេចយល់ជាងដល់ ព្រះឥស្សទិមិល បង្គាប់ជាងថ្វាត់ ហៃជាងចូរធ្វើ
ខ្លែងប្រាំពីរហត្ថ ឲ្យឆាប់ ៗ ថ្វាត់ ដូចដោយចិន្តា ៗ ជាង
ស្តាប់បន្ទូល ទើបជាងគិតគូរ ធ្វើខ្លែងហើយណា ប្រាំពីរហត្ថគត់
ប្រាកដគាលត្រា រួចចូលវន្ទា បង្គំថ្វាត់ថ្វាយ ៗ

## បទពុំនោល

ព្រះពោធិសត្វនោមឆាយ ជាងធ្វើខ្លែងថ្វាយ ស្រេចស្តេចបង្ហើរ

បណ្ណាល័យជាតិ

វេហាស៍ ៗ ព្រះមហាលើកករវន្ទា អធិដ្ឋានថា បពិត្រអស់ទេព
ទេវបុត្រ ៗ អ្នកចិតនៅទិព្យសមុទ្រ ហោមពាក្យប្រាកដ ចាតុម្មហា
រាជិកា ៗ ព្រះឥន្ទនរិន្ទថ្ងៃថ្លា សោឡសសួគ៌ា ស្តាប់ខ្ញុំបរបាប្រ
ណិធាន ៗ ដ្បិតខ្ញុំកើតទុក្ខពុំក្សាន្ត ពីស្រីកល្យាណ នាងក្រង
កម្រងមាលា ៗ ដ្បិតសាត់ព្រាត់ទឹកមកណា ចូលក្នុងហត្ថា នៃ
ខ្ញុំពិតពុំសង្ស័យ ៗ ពុំដឹងដម្រូវនាងនៃ ទិសទីបូរី បរមលំនៅនាង
ណា ៗ សូមអស់ទេវបុត្រទេវតា នាំខ្ញុំលេលា ស្មោះឆ្ពោះនគរស្រី
ថ្ងៃ ៗ ឲ្យខ្ញុំយាសយានខ្ញុំនៃ ដូចដល់បូរី ប្រាសាទប្រសើរ
សោភា ៗ ឲ្យបានចូលថ្កានជាយា ជារាជពនិតា ប្រាកដប្រកប
ជាក់ស្តែង ៗ ផ្សងស្រេចស្តេចចាប់ខ្សែខ្វង់ ទេវតាដំណែង ហើយ
នាំសម្តេចក្សត្រា ៗ អណ្តែតត្រែសែតវេហាស៍ លុះដល់នគរា បូបរម
រាជធាន ៗ ដល់ជាក់ក្សត្រាប្រធាន លើប្រាសាទឋាន នៃនាងសុ
រិយង់ឆាប់ឆ្វៃ ៗ ស្តេចចងខ្សែខ្វង់ហើយនៃ ព្រះនេត្រវៃ យល់
ទ្វារប្រាសាទជាយា ៗ ស្តេចផ្លង់កាណាក្សត្រា ស្តាប់សព្វវាចា
ក្សណាត្រព្រះបន្ទូលជាក់ ៗ និពានពីនាងវរលក្ខណ៍ នាងចូលសំ
ណាក់ លើគ្រែបន្ទំសុវណ្ណ ៗ ផ្អកផ្អឹះទង្គឹះខ្លាចផ្សា ស្រពោន
កន្ត្រា បន្ទូលថាឱ! ព្រាប់អ្វី ៗ ផ្កាក្រងកម្រងពិសី ផ្សងទៅរកប្តី
ម្តេចបាត់ពុំយល់ស្តេចណា ៗ ជាគូពិតពីបូរា បុរាណទើបផ្កា បាត់
ឈឹងពុំដឹងពត៌មាន ៗ បពិត្រទេវតាសព្វឋាន ជួយខ្ញុំឲ្យបាន យង់

យល់ព្រះភក្ត្រក្សត្រា ។ បន្ទូលស្រែបទើបជាយា សៀមស្ងាត់វាចា ស្រពោនស្រពាន់ភក្ត្រស្រី ។ ព្រះបាទនរនាថនរបតី ស្តាប់សព្ទសំដី ក្សត្រីបន្ទូលផាក់ស្បាន់ ។ ស្តេចប្រាបថានាងសោភ័ណ ផ្សងផ្កាស្រួពន់ ទៅដល់ប្រាកដគ្គាត់ណា ។ ស្តេចត្រីត្រួចប្រឹងភោមា ទើបយកមាលា ស្តេចផ្សងទៅកាន់ប្អូនស្រី ។ ឲ្យនាងជំងឺដើមសេចក្តី ជាព្រះចក្រី ស្តេចដល់ប្រាកដហើយណា ។ ផ្កាក្រងក្រមងមាលា ដូចដល់ជីតា ក្សត្រាចូលដល់ដោយពិត ។

## បទកាកគតិ

ព្រះពន្សពោធិ ចូលដល់ទេវី បន្ទូលសាសាត់ សាសន៍ស្ងៀម ប្អូនថ្លៃមាសមិត្ត កំប្អូនព្រួយចិត្ត បងដល់ហើយស្រី ។ ផ្សិតផ្កាកម្រង ដែលដៃប្អូនក្រង ទៅដល់បងខ្ញី បងឃ្លាតបរបាក លះលាកប្ញី បានដល់ប្អូនស្រី ឥឡូវនេះណា ។ ប្រប្អូនស្ងួនគ្រង នាងទទួលបង ឥឡូវស្រួសរក៏ ព្រះនុស្សបន្ទូល ខិតចូលម្មីម្មា ព្រះហស្តប្រាំ ឱបអង្គប្អូនស្រី ។ ដាក់ដល់លើភ្លៅ ថើបថៃដោយនៅ គូបកើតបេតី បិចម្លូលសុដន់ ស្រិតន់ប្រិមប្រិយ ខ្មាសព្រះចក្រី បម្រះចេញថ្ងាត់ ។ ទើបវរជាយា បន្ទូលត្រាស់ថា បពិត្រមហាក្សត្រ ស្តេចមករកអ៊ី តាំងពីត្រិស្ងាត់ ហាក់បានប្រតិព័ទ្ធ ស្និទ្ធស្នាលនឹងគ្នា ។ ម្តេចហ៊ានពេកពន់ ពុំហ៊ានគិតគន់ គួរគាប់ប្រាំ ចាប់ឱបថើបថៃ ស្នាលស្នេហ៍ស្និទ្ធគ្នា ពុំគោតបេស្តា ដល់បុណ្យគេសី ។ ខ្ញុំជាបុត្រក្សត្រ

គ្រប់គ្រងសម្បត្តិ សមបុណ្យបារមី ពុំជាស្រីស្រោល សាធារណ៍អ-
ប្រិយ ឃើញប្រុសដល់ទី ដល់ទៃទបន្ទុំ ។ ប្រុសឱបប្រែឡែង
អរអត់ឲ្យលែង ផ្តេកផ្តួលម្នោរម្យ ពុំមានកេរ្តិ៍ខ្មាស អស្រូវកាសងំ
ខ្លួនខ្លះក្រមុំ ពុំដឹងនិន្ទា ។ បពិត្រខ្លួនខ្ញុំ ជាស្រីពិតពុំ ពាន់ស្គាល់
ប្រុសណា ចូលដល់ឋានចិត ទៀតជិតអង្គា ដូចព្រះរាជា ហាក់
ហ៊ានពេកពន់ ។ ស្ដេចស្ដាប់សំដី សម្ដេចភូមី ឆ្លើយស្នងប្អូនគន់
ហៃមេមាសមិត្ត គំនិតស្រីធ្ងន់ បងបានជាស៊ុន យល់ខុសផ្គាំផ្គង ។
គឺមោះគេជា នាងផ្សែងមាលា ឲ្យទៅដល់បង បងមកតាមផ្កា មាលា
កម្រង ផ្កាប្អូននាំបង ដូចដល់ស្ងួនភ្ងា ។ ស្ដែងស្ដេចលោមនាង ព្រះ
ហស្ដអំពាង ឱបអង្គជាយា ទើបថៃសព្វាង្គ អង្គនាងប្អូនភ្ងា បិចមួល
ស្នេហា សំណេះសាសង ។ ហៃប្អូនមាសមិត្ត នាងល្អៈពេញចិត្ត
ត្រូវទឹងភ្នែកបង ព្រះហស្ដសស្ទួល មិត្តមូលបំព្រង សក្តិសមសុរង
ផ្គត់បីជាន់ជុំ ។ ព្រះភក្ត្រប្អូនស្រី ដូចចន្ទបូណ៌មី ភ្នីផ្ទេកសសម សុ-
ជនពីរពេញ ស្រស់ស្រេចដោះក្បំ ហាក់ដូចបទុម ពេញពីទក់ ។
ព្រះអង្គកែកាយ ស្លូលស្រស់ឆេតឆាយ កបកលលក្ខណា ព្រះឱស្ឋ
ញញឹម ប៉ប្រិមជិតស្លា សើចសមទន្តា ត្រឹមត្រូវល្អល្អះ ។ ព្រះ
នេត្រថ្វាយង់ ថ្វាយល់បញ្ចាង់ បុណ្យបងប្រែខៈ ដូចនឹងប្អូនស្ងួន ក៏នខ្លួន
គ្រចះ គ្រចង់ស្រឡះ ពពកមេឃា ។ នាងស្ដាប់ព្រះបង ពុំចេញ
សាសង សាសព្វាកា អៀនឱនព្រះភក្ត្រ វរលក្ខណ៍ជាយា ទើប

ព្រះរាជា ថ្នាក់ថ្នមមហេសី ៗ ព្រះពោធិសត្វ ទឹងនាងស្រីរតន៍ រួម
រក្សបតី ស្នេហាជួបជិត មូលមិត្តមេត្រី សម្រេចដូចក្តី បំណងប្រា
ថ្នា ៗ នាងកេតសុរិយង់ លុតលើកកំបង់ បង្គំទូលថា បពិត្រព្រះ
បាទ នរនាថថ្លៃថ្លា ព្រះអង្គជាតិជា ឥស្សរកេពត្រៃ ៗ ស្តែងស្តេចជា
ក្សត្រ សោយរាជសម្បត្តិ ឫទេពតាថ្លៃ ឥន្ទ្រព្រហ្មសោតសព្វ គន្ធព្វ
នាគនៃ សូមព្រះបក្រី ប្រាយប្រាប់ប្អូនក៏ ៗ ស្តេចស្តាប់ទំនូល
ព្រះឱស្ឋមធុរ ប្រាប់ព្រះប្អូនក្យា ឫខ្លួនអញបង់ គប់គង់ភាព ជាតិ
ជាមនុស្ស ទគរព្យតេន ៗ បង់ឈ្មោះព្រះសុ វណ្ណហុងឥតគូ
ជាតិមហាក្សត្រ ឯព្រះបិតា ស្នេហាប្រតិព័ទ្ធ ឈ្មោះសុធនវ័ត្ន ឥស្សរ
ត្រាមា ៗ រីព្រះជនី នាមឈ្មោះនាងស្រី កែវសុចិត្រា ព្រះអង្គ
សាទរ ឈ្មោះសរមេត្តា ឲ្យបង់យាត្រា មុះមករកពៅ ៗ ផ្សង
ខ្វិនហើយហោះ ទេវតានាំស្មោះ ដម្រង់សំដៅ ប្រាសាទប្អូនស្រី
ប្រិមប្រិយពាលពៅ ហេតុសំណាងពៅ ទឹងបង់ប្រិនជាតិ ៗ នាង
នាថទទួល ស្តាប់ព្រះបាទបង ថ្លែងប្រាប់អស់អាថ៌ ប្រាប់អស់សេចក្តី
ក្សត្រីវិន្ទា ទូលក្សត្រនរនាថ ឥស្សរសិរសា ៗ បពិត្រសូមទាន
សព្វថ្ងៃខ្ញុំគ្មាន ព្រះវរមាតា ព្រះអង្គក្សិណក្ស័យ ប្រល័យជន្មា នៅ
តែបិតា គប់គង់បូរី ៗ ឥឡូវនេះណា ខ្ញុំផ្ញើជន្មា ទឹងព្រះបក្រី ជា
ខ្ញុំព្រះបាទ នរនាថនរបតី សូមស្តេចមេត្រី កុំបង់ឃាតឃ្លា ៗ ព្រះ
ពោធិសត្វ បើកបន្ទូលថ្លាត់ ថាហៃប្អូនក្យា កុំមោសមិត្ត ព្រួយចិត្តចិត្តា

ក្រដាម្ដេចម្ដា បង់ពុំបោលទៅ ៗ ស្ដេចថ្នមប្អូនស្រី ថៃះចីបសិរសី លើកដាក់លើភ្លៅ សោមនស្សាសាទ្ត ពុំមានហ្មងសៅ រៀបព្រឹកព្រះចៅ លាព្រះប្អូនស្រី ៗ ស្ដេចស្រាយខ្សែខ្វង់ នាំហើរលះលែង ប្រាសាទសួស្ដី ស្រេចដល់ដើមជ្រៃ មួយនៃចក្រី សំណាក់សព្វថ្ងៃ លុះព្រះសុរិយា ៗ ប្រលច់យប់ជ្រៅ ព្រះបាទចមះចៅ ស្ដែងស្ដេចយាត្រា ជុំទង់ប្អូនស្រី សព្វថ្ងៃទៅណា លុះទៀបវេលា ស្ដែងស្ដេចចេញចរ ៗ

## បទព្រហ្មគីតិ

លុះព្រឹកព្រាងស្រាងស្រេច ក្រោយសម្ដេចព្រះកុមារ ស្ដេចលេលាចេញចរ ទើបក្សត្រីស្រីកញ្ញា ៗ នាងតើនចាកបន្ទំ រ័ត៌នុត្តមហើយផាយា លប់លាងព្រះភក្ត្រា បរិបូណ៌ហើយនាងគង់ស្កល់ ៗ កិលៀងតាំងប្រុំប្រាណ ស្រង្គារមានមកគាល់ហ្វៅ ពេញពាសជេរផាសនៅ នៃបព្រះអគ្គិវរក្សត្រី ៗ គីលៀងគយគន់មើល យល់ជំណើរកាជទេពី ផ្ទែកអគ្គិគាប់រស្មី ពុំគង់នៅដូចសព្វដង ៗ កេះកៀវខ្សិបខ្សៀវរក គ្នាទៅមកទីងផ្អៀងផ្អង លួចលបមើលម្ដង ៗ យល់ចុងដោះខ្មៅពុំដិត ៗ លុះស្គាល់ស្រេចហើយនៃ កិលៀងរេវះគន់គិត ថាក្សត្រីស្រីរ័ត៌ន ហាក់មានហេតុការស្ទាស្ទន់ ៗ យើងនៅនេះសព្វគ្រា ប្រសពីណាហ៊ានពេតពន់ ចូលដល់ទីដម្បូន់ យើងពុំដឹងដល់គិចនៃ ៗ ខ្វះថាអញដេកនៅ មាត់ទ្វារក្រៅតែង

វែត ពុំឃើញមនុស្សចាំផ្ទៃ បើកទ្វារចូលមកពីណា ។ ខ្វះថា
មហើយអញ ឯងដេកពេញនៅផងគ្នា លុះលង់ស្កប់និទ្រា ដូច
ខ្មោចស្លាប់ប្រហាមាត់ ។ គេចូលដាន់លើខ្លួន ពុំក្រាក់សូម្បីសុងបាត់មាត់
ម៉្លោះហើយកុំសាសាក់ ល្ងាចនេះយើងមើលមួនមាំ ។ កុំដេកឲ្យលក់
ឡើយ ធ្វើព្រងើយហើយឃ្មាំចាំ ឲ្យឃើញជាក់ទីងនាំ គ្នាចូលទូល
ព្រះបិតា ។ លង់លុះចូលពព្រឹ ភិលៀងស្រែកគិតគ្នា គយឃ្មាំ
ចាំពជា វាដេកពុំលក់ដល់ម្នាក់ ។ ក្សណនោះរាជក្សត្រ យល់
អស់ស្រីដេកពុំក្រាក់ នាងចរចេញសំណាក់ បើទ្វាររង់ចាំពជា ។ ទើប
ព្រះសុវណ្ណហង្ស ពេលស្តេចទ្រង់ឆាកខ្លួនណា ហើរហោះដល់ប្រាង្គ
ប្រា- សាទនៃនាងនាថសោភ័ណ ។ កាលណោះភិលៀងប្រាំ វា
ឃ្មាំចាំយល់ជាក់ស្ប៉ាន់ លបលួចមើលស្រកាន់ ថាអ្នកនេះល្អពន់ពេក ។
ហាក់អង្គព្រះឥន្ទ្រព្រហ្ម រូបសក្តិសមល្អចំឡែក គ្នាយើងដល់ថ្ងៃស្អែក
យើងចូលទូលព្រះបិតា ។ ឲ្យជ្រាបព្រះហឫទ័យ កាលណោះនៃ
ទើបយើងជា បើពុំទូលក្សត្រា សមយើងក្ស័យជីវិតបង់ ។ ភិលៀង
មួយធ្លាស់ធ្លើយ កុំចូលឡើយអញគិតបង់ ឲ្យជាងធ្វើយន្តផង ជាលំ-
ពែងចាក់ឲ្យក្ស័យ ។ ភិលៀងគិតព្រមស្រេច មួយរំពេចពុំនាំពា លុះ
ព្រឹកល្មមវេលា ស្តេចចេញចាកព្រះបូនរ័តន៍ ។ ចាប់ខ្សែខ្លួនហើរ
ដល់ ផ្ទៃសួរសល់ទីឋានស្ងាត់ ព្រះពន្លឺរោចនិសក្ត ផ្ទំសុខលក់ង
ឥជ្យាន ។

លេខកូដ :

## បទពំនោល

ក្រោយគិលៀនតាំងប៉ុំប្រាណ ដែលក្រៀកពលហ៊ាន ឲ្យគេដាំយន្ត មកឆាប់ ៗ ដាំងអើយព្រះស្នែងបញ្ជាប់ ធ្វើយន្តឲ្យឆាប់ លំពែង ដាក់ទ្វារប្រាសាទ ៗ បើចូលកុំយូរឃ្លាឃ្លាត យន្តវាក់ខ្ទីឃ្លាត ពិឃាតឲ្យក្ស័យជន្មា ៗ ដាំងស្តាប់សាសព្វកថា ស្រេចដាំងធ្វើជា លំពែងយន្តស្រេចហើយនៃ ៗ លុះព្រះសុរិយាល្ងាចថ្ងៃ យប់យូរ ស្រីថ្ងៃ ចេញបើកទ្វារចាំមហាក្សត្រ ៗ ហើយនាងលេលាចូល ប៉ាត់ បន្ទំរម្យរ័ត្ន ផ្ដុលកំពុងដង់ដើមក្ដី ៗ គិលៀនយកលំពែង ដ៏យ ដាក់ទ្វារហើយនៃ សម្ងំឃ្លាំចាំមើលគល ៗ ទិតានក្សត្រ ក្សាន្តនិមិល ស្តែងស្តេចគង់ស្តល់ ក្រោមដើមព្រះដៃសាខា ៗ ហេតុកម្មនាយខាំក្សត្រា ឲ្យក្ស័យជន្មា ប្រាកដពិតពុំឃ្លាតឡើយ ៗ លុះយប់យូរតិចហើយ ក្សត្រាត្រាណាតើយ ទង់គ្រៀងរុងរៀងសោ ភា ៗ កាលណោះទេព្រក្សរក្សា ព្រះដៃសាខា យល់ជាក្សត្រាក្សណ ក្ស័យ ៗ គិតថាបើស្ងៀមហើយណា អញខុសសោះសា ហាក់មើលបំ ណាំកជា ៗ គួរអញក្រាបទូលក្សត្រា ឲ្យជ្រាបទយា ទើបត្រូវគន្ធធម៌ គាប់ៗ ទេព្រក្សក្រាបទូលបញ្ជាប់ បពិត្រចូរស្តាប់ ខ្ញុំទូលឲ្យជ្រាប ព្រះម៉យ ៗ តទ្បូវកុំទៅឡើយនៃ ទៅហើយសមក្ស័យ ជីវិតពុំលែងឡើង ណា ៗ ដ្បិតគេដាក់លំពែងជា យន្តសព្វមាគា ជោយទ្វារប្រាសាទរ៉ូង ខ្ទាត់ៗ ខ្ញុំទូលអង្វរសូមឃាត់ បើទៅសមក្ចាត់ ប្រហារជីវិតមរណា ៗ ស្តេច

បានស្តាប់ទេព្រក្សថា ឃាត់ព្រះរាជា កុំឲ្យបរចេញចូលឋាន ។ ស្តេចមាន បន្ទូលទៅក្ពាន ហៃទេពប្រធាន អញកុំជឿពាក្យអ្នកឡើយ ។ ដ្បិត ក្សត្រិយ៍តែនត្រាណាត្រើយ ផ្តាំឲ្យទៅហើយ កុំគួរទើសគិតផ្ទុយនោះ ។ ដ្បិតចិត្ត ស្រឡាញ់អញស្មោះ កុំគួរធ្វើនោះ អញកុំខានដូចអ្នកថា ។ ស្តេច ស្រាយខ្សែខ្វង់ហើយណា គេបហើរលេលា ទៅដល់ប្រាង្គប្រាសាទ រ័តន៍ ។ មានហេតុបរបាក់មួយស្ពាក់ ព្រះភក្ត្រមហាក្សត្រ ព្រះមកុដ ធ្លាក់ពីកេសា ។ ស្តេចយកព្រះហស្តថ្ងៃថ្លា ទន់ទ្រមាលា ព្រះ បាទស្តេចធ្លាក់ក្បែរទ្វារ ។ ស្ទុះចូលរំពេចដល់ឋាល លំពែងយន្ត ទ្វារ បាក់ត្របុកព្រះរ័តនថ្ងៃ ។ ដួលចុះសន្ធប់ដល់ព្ញ មាត់ទ្វារស្មើរ ក្សយ ជីវិតស្មើរទើសមរណា ។ លុះភ្ញាក់ស្មារតីក្សត្រា យកព្រះហស្ត ប្រពាបាប់ផងលំពែង ។ ឈាមហូរពាសពេញគួរស្ញែង ព្រះទស្ស ថាថ្ងែង ទន់ព្រះទំនួញទួញថា ។

## បទកាកគតិ

ឱ ! កេតសុរិយង់ បងស្មានចិត្តត្រង់ ចិត្តត្រូវទើសគ្នា ម្តេច ឡើយចិត្តកាច កំណាចមហិមា បាក់បងប្រាថ្នា ឲ្យស្លាប់បងបាត់ ។ កេតសុរិយង់អើយ កម្មពៀនឯងហើយ ឲ្យបងភ្ញាំងភ្ញាត់ ពួនដេក ព្រងើយ កុំធ្វើយសារសព្ទ បំណាច់បងកាត់ ចិត្តមករកបៅ ។ គិត ថាស្រីស្រួល ស្រីស្រស់អនុកូល រក្សាគ្នាទៅ បងមិនដឹងតែ ជាមេ ស្រីពៅ នាងល្អពេកបៅ បាក់បងឲ្យក្ស័យ ។ ពិសពើបទៀប

ហើយ ខ្មោចផ្សាដូចភ្លើង ពន្លឺពេកក្រៃ ស្តេចទប់ពុំបាន ប្រះប្រាណដល់ដី នទៀលនៅនៃ ភាគផែនពសុធា ៗ ស្តេចខំទប់ទល់ ប្រឹងប្រាណដំកល់ ស្មារតីទ្រូញថា ឱះឱ! កម្មព្រេង វេទ្ធង អាត្មា ឲ្យក្ស័យជន្មា និត្យនៅម្នាក់ឯង ៗ ម៉្លេះសមបិតា មាតា ស្ងួនភ្ងា ចាំងពីរស្តេចតែង ទន្ទឹងកូនបាត់ សូត្រស្វាត់កណ្តែង កណ្តោចស្តេចវង្ស ទ្រូញទល់ទុក្ខា ៗ ពុំដឹងជាកូន ក្សិណ ក្ស័យសោះសូន្យ ជីវិមរណា ស្មានជារូបរស់ ជាមនុស្សទ្រឹងយា- ត្រា ត្រាច់លេលា ដល់កផបូរី ៗ ស្តេចទ្រូញហាហៅ ហៃមាសស្រីពៅ ពាលពេញពីសី បងនឹងមរណា កាលត្រាំទះនៃ ចូលមាសប្រិមប្រិយ ចេញមកក្រៅក៏ ៗ ឲ្យបងយល់អង្គ មាសមេវរង្ស សោះបងខ្មោចផ្សា បងនឹងផ្តាំទៅ ប្អូនពៅពុំឃើ ម្តេចឡើងស្ងួនភ្ងា ពួនពង់និត្យនៅ ៗ ឱ! កេតសុរិយង់ ម្តេចចិត្តពុំត្រង់ ពុំត្រេកណាទៅ បងស្រឡាញ់ស្រី បេតីឥតសៅ បងស្មានថាទៅ ស្មោះស្ម័គ្រចិន្តា ៗ ព្រះហស្ត ស្តេចស្តែង ចាប់ដងលំពែង ឈាមហូរធារា ពាសពេញព្រះអង្គ លន់ លង់នេត្រា បន្ទូលត្រាស់ថា រូបអើយអាសារ ៗ ស្រឡាញ់តែ ស្រី ទុកចិត្តជាប្តី ប្រពន្ធពេញពាល ខ្លួនស្លាប់ពុំគិត គំនិតសាធារណ៍ ព្រោះវៀតស្រីប្រសាល បោលរូបបងបាត់ ៗ ឱ! កេតសុរិយង់ បង ពុំស្លាប់ក្តុង នគរនាងថ្វាត់ បងនឹងលេលា យាត្រាធាប់ក្តាត់ នគរញ្ញ រ័តន៍ ស្រុកបងនាយនៃ ៗ បន្ទូលម៉្លោះស្រេច កាលណោះទើប

ស្ដេច យកព្រះហស្ដថ្វៃ ឈោងចាប់ខ្សែខ្វែង ខះខែងធាប់វៃ រលូត
ពីដៃ ទ្រេតទ្រោតដួលចុះ ។ ឈាមហូរស្រោក សស្រោចគគ
អាក់ ខែងខំស្ទាញស្ទុះ ទប់ទល់អង្គា ប្រឹងឡើងស្ទោះ ចាប់ខ្សែ
ខ្វែងហោះ ហើរចេញដោយខ្យល់ ។ ស្ដេចខំគោងខ្ទប់ ខ្វែងហើរ
ប្រញាប់ ស្រេចទើបស្ដេចដល់ ប្រាសាទរតនថ្វៃ ប្រពៃស្ដួគិសល់
ស្ដេចចូលមណ្ឌល ខែទកែវក្រឡា ។ បន្ទំក្សត្រថ្វៃ ស្ដេចទំពរវៃ យក
ព្រះហត្ថា ចាប់ព្រះពស្ដ្រថ្វៃ ទោះនៃសាកា ទទួលអង្គា ប្រះប្រាណ
ដេកថ្ងាត់ ។ ក្សិណក្ស័យព្រះជន្ម រំពេចក្នុងមណ្ឌ- លទ័រម្យរ័តន៍
ឯអស់បរិពារ គេះគោះប្រេីនក្ដាត់ ពុំដឹងជាក្សត្រ ដួលដល់ក្រលា ។
អករយាយស្រង្គារ ឃើញឈាមដេរដាស ស្រប់ស្រោចនៅនា ក្នារ
ប្រាសាទថ្វៃ ភិតភ័យមហិមា ការចូលមីមា មើលយល់មហាក្សត្រ ។
ឃើញជនល់ពែង ជាប់ព្រះអង្គស្ដែង ចរចូលប្រណិប័តន៍ ពុំព្រ
ទស្ដា ក្សត្រាស្ងៀមស្ងាត់ ចូលជាស់មហាក្សត្រ អង្រួនអង្រួន ។
ពុំដឹងព្រះអង្គ ស្រេចនះឡើនលង់ ជោឡោប្រពូន ដឹងជាស្ដេចក្ស័យ
ប្រល័យសោះសូន្យ ភ័យញ័រអស់ខ្លួន ទួញទល់ទុក្ខា ។ ខ្ញុះរត់
ចរចូល គាំងទឹកក្នុកហូរ ដល់ព្រះបិតា ប្រណម្យទៀងទូល ដោយ
បូរាបា រាជបុត្រក្សត្រា ចូលក្នុងបន្ទំ ។ ក្សិណក្ស័យព្រះជន្ម
គេចាក់ពីមណ្ឌ- លណាពិតពុំ បានដឹងហេតុកិច្ច កលស្ដេចសូមសម្ដេ-
ចជ្រាបអស់ដំ- ណើរនៃអត្ថា ។ ជនកជនី ស្ដាប់អស់វាក្យស្រី

ទូលហើយក្រោត ភ័យញ័រព្រះអង្គ ស្ដេចទ្រង់សោកា សុរេត ម្នីម្នា ដល់ព្រះរាជបុត្រ ។

## បទព្រហ្មគីតិ

ពីរក្សត្រសែនសោយសព្វ ញ័របំប្រែប់អង្គរន្ធត់ ទួញថាទិបាបុត្រ ម្ដេចមកក្ស័យនៃជន្មា ។ កាលកូនមាសទៅលេង ក្រសាល ល្បែងបានមាលា យំទួញទល់ទុក្ខា អាពុកឲ្យផ្សងខ្លួនទៅ ។ កូនមាសមិត្តស្នេហ៍ស្នង ទៅហើយហេតុម្ដេចកូនពៅ ឲ្យគេចាក់- សំដៅ ត្រង់ទ្រូងរ៉ែតទីមិល ។ បាវិលមកដល់ឋាន ឪពុកបាន ឃើញបុត្រមរណ៍ កូនអើយអាពុកទល់ ទុក្ខខ្ទាំស្ទើរក្សិណក្ស័យ ។ អាពុកម្ដាយជរា សង្ឃឹមបាបុត្រចិញ្ចឹមថ្ងៃ នឹងគ្រប់នឹងគ្រងផ្ទៃ ស្នង អាពុកជ្រិតជរា ។ ឥឡូវបាក្សិណក្ស័យ អ្នកណានៃគងរដ្ឋា តាង កូនមាសពុំងា អាពុកទល់ទុក្ខជូនក្រៃ ។ ស្ដេចទួញ ៗ រាជបុត្រ ញ័ររន្ធត់ស្ទើរក្សិណក្ស័យ បន្ទោសោកហើយនៃ មានបន្ទូលត្រាស់ទៅ ថា ៗ ហៃអស់ទាំងមន្ត្រី ចូរឆាប់វៃ សម្នីម្នា ធ្វើមឈូសមាស សោកា ឲ្យប្រញាប់កុំផ្សរផ្សង ។ ហើយឲ្យធ្វើប្រដាប់ មេរុមណ្ឌប កុំឲ្យលង់ ធ្វើបុណ្យបុត្របញ្ចង់ ចូរប្រូសរៀបឲ្យឆាប់ ៗ ។ អស់ មុខមន្ត្រីផង ស្ដាប់ក្សត្របង្រទ្រង់បង្គាប់ ចេញទៅរៀបប្រដាប់ នាំ ព្រះឋានចូលថ្វាត់ថ្វាយ ។ ស្ដេចដាក់ព្រះសពស្រេច ហើយទើប ស្ដេចឲ្យខ្វល់ខ្វាយ ធ្វើមេរុមាសពណ្ណរាយ នឹងដំកល់ព្រះសពក្សត្រ ។

និទាននេះទុកនៅ ស្រដីទៅឯស្រីរ័តន៍ សុរិយន៍តើនឡើងថ្កាត់ ទន្ទឹងគិត

ព្រះរាជា ៗ យល់បាត់យូរពេកក្រៃ នាងស្រីថ្លៃគិតខ្លាចផ្សា

ទន្ទឹងព្រះរាជា លង់លុះដល់ព្រឹកភ្លឺស្វាង ៗ បើកទ្វារប្រាសាទ

រ័តន៍ ព្រះនេត្រក្សត្រទតអស់ក្បាន យល់ឈាមពាសពេញប្រាង្គ ប្រា

សាទទើបទតយល់ខ្សែ ៗ យន្តដាក់នៅមាត់ទ្វារ ទើបជាយា

គិតថប់ថៃ ឱសមព្រះមាសស្នេហ៍ ត្រូវលំពែងយន្តហើយនៃ ៗ នាង

ទួញញ័ររន្ធត់ ស្ទើរទន់ផុតជីវិតក្ស័យ ឱអ្នកណាចង្រៃ ផ្ដាញជីវិតព្រះ

រាជា ៗ នេះសមកិលៀនប្រាំ គិតឃ្មាំចាំហើយទើបរ ដាក់លំ

ពែងយន្តណា ចាក់ព្រះអង្គឲ្យក្សិណក្ស័យ ៗ ឱកាលកម្មអ្វី ដេក

ពិតពុំភ្ញាក់ឡើយនៃ ម៉េះសមព្រះជៀសជ័យ ស្ដេចទៅគេមហាខ្ញុំថ្កាត់ ៗ

ខ្ញុំពុំភ្ញាក់ស្មារតី សមបក្រស្ដេចចេញបាត់ ហោះហើរដល់ឋានបិត

សម្ដេចក្ស័យនៃជន្មា ៗ ឱមាសថ្លៃឧត្ដម ស្ដេចចោលខ្ញុំនៅឯកា

ពុំយកប្អូនទៅជា បាទបរិចារិកចោលលះបង់ ៗ ឱព្រះមកប្រសប់

បានបីយប់ទេព្រះអង្គ មាសមកបំបាត់បង់ ព្រះពីទ្រង់ប្អូនឃ្លាតឃ្លា ៗ

ឱខ្លួនប្អូនជាស្រី ធ្វើម្ដេចនៃទីងយាត្រា ទៅតាមព្រះរាជា ឲ្យ

បានយល់ព្រះភក្ត្រក្សត្រ ៗ នាងសោក ៗ បម្រះ នាង

អន្ទះអន្ទែងក្ដាត់ នាលោហិតមហាក្សត្រ ញ័ររន្ធត់អស់ទ្រង់ ៗ

## បទកាកគតិ

ក្សិណនោះអស់ស្រី តាំងប្រាំស្រដី ខ្សឹបខ្សៀវកាន់គ្នា យល់ក្សត្រី

សោក អាមោកខ្លោចផ្សា បបួលអស់គ្នា ចេញច្ឋានទេវី ។ ញ
ញ៉ឹមស្ងួរសោទ្ត ចំអកថាមាន ហេតុការណ៍កលអ្វី នាងនាថសោយ
សោក វិយោគសែនថ្វី ស្រីសោកអំពី តែស្តេចសុគត ។ រីមាន
ស្វាមី សុគតនៅទី ណាប្រាប់យើងថ្វាត់ យើងនឹងជួយជប់ លើក
សពមហាក្សត្រ ចូរនាងសាសាត់ ប្រាយប្រាប់យើងក៏ ។ សុរិ
យង់ទេវី ស្តាប់ពាក្យអស់ស្រី នាងខ្មាសមហិមា ធ្លាស់ឆ្លើយស្នង
វិញ ថាអញលោកា ម្តាយនាងគ្រប់គ្នា ស្វាប់បាត់ឥតគ្តី ។ ឈឺ
ក្បាលអ្វីនាង ធ្វើជាបេះដាង មានមាត់ស្រីដី បើស្វាប់អសារ ឥតការ
ទៅនៃ បើរស់ជីវី ឃើញគ្នារត់ទៅ ។ បន្ទូលស្រែបហើយ ក្សត្រ
ត្រាណត្រើយ ចូលក្នុងលំនៅ កំនត្វារប្រាសាទ ឈឹងស្វាត់ស្រី
ពៅ ទូញរកព្រះថៅ សន្ទប់លុះលង់ ។ លុះភ្ញាក់ស្មារតី សោយ
សោកសែនថ្វី គគត់ទ្រូងទ្រង់ ទូញថាព្រះមាស ម្តេចព្រះបោះបង់
សម្បូនពុំគង់ ជីវិតមរណា ។ បើប្អូនរួចរស់ ជីវិតជាមនុស្ស ខ្មាស
ពាក្យនិន្ទា សូវស្លាប់បង់បាត់ សូន្យស្ងាត់វាចា ខ្មាសពាក្យគេថា
សូវស្លាប់គាប់ត្រៃ ។ ឱក្សត្រឧត្តម ស្តេចស្រឡាញ់ខ្ញុំ ទើបមកពី
ភ័យ យុវត្តិ៍សេមា ប្រាថ្នាមូលមៃ ត្រីត្រែកហឫទ័យ ស្មានជា
សប្បាយ ។ នាងសោកព្រះរៀម ព្រះកក្តិក្រំក្រៀម គន់គិតសព្វ
សាយ នាងនឹងបរត្រាច់ តាមស្តេចទៅឆ្ងាយ ឲ្យស្លាប់អន្តរាយ
កណ្តាលដងព្រៃ ។ លុះចូលសន្ធ្យា ព្រលប់ហើយណា សម្តេច

ក្សត្រិ លើកករកំបង់ ផ្ចិតផ្ចង់សិរសី ស្មោះស្ពោះប្រណិ ធានទេព
ទេវា ៗ បពិត្រព្រះអង្គ ប្រសើរស្តេចគង់ ឋានត្រៃត្រឹង្ស ជាតិ
ជាព្រះឥន្ទ្រ នរិន្ទ្រថ្លៃថ្លា ទោះទាំងទេវតា សោឡសសួស្តី ៗ សូម
ជួយខ្ញុំផង ខ្ញុំទឹងបរផ្គង តាមព្រះបក្រិ ក្នុងកត្រីស្ងាត់ ត្រាច់កាត់
ព្រឹក្សព្រៃ កុំឲ្យអស់ស្រី រកខ្ញុំឡើយណា ៗ កិលៀងទាំងប្រុំា ពា
គយឃ្យាំចាំ ពិកក្តិរក្សា ទាំងព្រះជនក សោយសុខត្រាមា កុំឲ្យទឹក
នា រកខ្ញុំឡើយនៃ ៗ ទោះទាំងសេនា គបេលក្សាតមាត៌ា សក្ខុជាយ
ផ្លូវព្រៃ កុំឲ្យឃើញខ្ញុំ ខ្ញុំខំឃ្លាតខ្លី តាមព្រះបក្រិ ឥឡូវនេះណា ៗ
ផ្សងស្រែបទេវី លេលាចុះពី វែនទិព្វក្រឡា ដល់ក្រៅពដវាំង ដើរ
ខ្លាំងមហិមា អស់ពលយក្សា ដេកអស់ពុំមាន ៗ រលឹកដល់ម្នាក់
នាងនាថវរលក្ខណ៍ ត្រាច់ដើរតាមផ្លាន ឈាមស្រកថ្លា ៗ ក្សត្រិ
កល្យាណ ពុំឈប់សម្រាន្ត ខិតខំយាត្រា ៗ ចូលព្រៃលិចពល
ឆ្ងាយជាច់ស្រយាល ពុំដឹងគណនា លុះដល់ព្រៃធំ ទុតិមអត្វា បាត់
ឈាមក្សត្រា នាងនាថវិលវល់ ៗ ពុំដឹងទិសទី សម្តេចទេវី ប្រះ
ព្រាណសោកសល់ ទួញទ្រង់កន្សែង ថ្ងឹងថ្ងៃឥតកល ពិតពុំទប់
ទល់ ទៀងទួញថប់ថា ៗ ឱម្ចាស់ឧត្តម បាត់ឈាមខ្ញុំពុំ ដឹងដើម
ក្សត្រា ស្តេចទៅណានៃ ក្សត្រក្សួយជន្មា ត្រង់ទិសឋានណា ពុំ
យល់ព្រះបង ៗ បើថ្ងៃមិនមរណ៍ ឲ្យឃើញកូធរ សិមមរណ៍មូលផង
ជាមួយនឹងគ្នា កាលត្រានេះម្តង ខ្ញុំពុំរស់រង រស់រួចជន្មា ៗ នាង

ទួញសព្វគ្រប់ ប្រះប្រាណសន្ធប់ ស្មើរក្ស័យជន្មា ពុំភ្ញាក់ស្មារតី

ក្សត្រីកញ្ញា ដួលដេកនៅនា ភាគផែនធរណី ។

## បទពំនោល

ទឹងថ្លែងសំដែងស្រដី សម្ដេចកាសី ព្រះឥន្ទរិទ្ធិថ្លៃថ្លា ។

ស្ដេចគង់នៅត្រែត្រឹងត្រា សាន្តសុខទយា ឥតមានរំជួលព្រះទ័យ ។

កាលថ្ងៃក្សត្រីល្មមល្មៃ តាមក្សត្របមត្រែ សន្ធប់ស្មើរទឹងមរណា ។ ស្ដេច

ដល់មណ្ឌលអាស្នា សម្ដេចឥន្ទ្រា មានព្រះបន្ទូលស្នេហ៍ស្ងួន ។ ហ៊ះ

មានហេតុកេទម្ស៊ីហោង ក្ដៅក្ដាត់កន្ទួង ទឹងគង់ពុំសុខឡើយនៃ ។

ព្រះឥន្ទរិទ្ធិថ្លាថ្លៃ ទតនេត្ររំពៃ សហាស្រ្យនឹងយល់ធីតា ។ ថា

ហើយអស្ចារ្យនេះណា ដ្បិតរំជាយា លេលាតាមរកស្វាមី ។ ពុំដឹង

ទិសទីឡើយនៃ ដួលដេកដោយដី ស្មើរក្ស័យជីវិតមរណា ។ គួរ

អញបរបេញលេលា ទៅជួយធីតា ឲ្យបានដូចចិត្តបំណង ។ ស្រេច

ស្ដេចលេលាហោះផ្សង ។ ឆាប់ក្រៃកន្ទង ស្រេចដល់នាងនាថធីតា ។

យល់នាងសន្ធប់នៅនា ពុំភ្ញាក់អាត្មា ក្សត្រាយកទឹកគន្ធ ។ លប់

លាងព្រះភក្ត្រក្សត្រី សម្ដេចកោសី ស្ដេចដាស់នាងនាថឡើងថ្កាត់ ។

កាលណោះក្សត្រីស្រីរ័ត្ន ភ្ញាភ្ញាក់ទើបក្សត្រ កោសីនរិន្ទថ្លៃថ្លា ។

ដណ្ដឹងរ័តនពជជាយា ហៃនាងសោភា ម្ដេចមកតែឯកអង្គឯង ។ បរ

បាកលះលាភចំបែង រកអ្វីចូរថ្លែង ប្រាយប្រាប់ឲ្យបានដឹងក៏ ។ នាង

កេតសុរិយង់ថ្លៃថ្លា ស្ដែងស្ដាប់វាចា សម្ដេចកោសីធិបតី ។ នាងនាថ

ក្រញ្ញក្រាបសិរសី ទូលព្រះកោសី ដូចដោយដំណើរអត្ថា ។ បពិត្រ
សូមជ្រាបទយា ដ្បិតគិលៀនផង ចាក់ព្រះស្វាមីខ្ញុំបង់ ។ ស្តេចលេ
លាទៅក្តោះត្រង់ នគរព្រះអគ្គ សមក្ស័យជីវិតមរណា ។ ខ្ញុំរត់តាម
ឈាមពាដា ពុំដឹងទិសា ឈាមបាត់ពុំយល់ឡើយនៃ ។ នាងទូល
ស្រេចហើយស្រីថ្ងៃ សែនសោយសោកក្រៃ ញាប់ញ័ររន្ធត់អគ្គា ។
ព្រះឥន្ទទ្រង់ថ្លៃថ្លា ឥតសូរធីតា មានព្រះបន្ទូលសាសង ។ កុំនាង
ព្រួយគិតព្រះបង អញជួយនាងហោង ឲ្យឃើញសម្តេចក្សត្រា ។
ឲ្យថ្នាំព្រេងទិព្វថ្លៃថ្លា របស់ព្រះកជា ឲ្យរស់ជីវិតឡើងថ្វាត់ ។ ដ្បិត
នាងក្សត្រីស្រីរ័ត្ន ស្នេហាប្រតិព័ទ្ធ សុតត្រង់នឹងព្រះស្វាមី ។ កាត់
ចិត្តប្រាកដតាមប្តី ទោលពជប្រី ពុំដឹងជីវិតមរណា ។ ហើយឲ្យនាង
ប្រែក្រឡា ជាព្រាហ្មណ៍ហើយណា ទើបទៅដល់ពជប្រី ។ នគរទេព្វ–
រ័ត្នឆ្ងាយក្រៃ នាងទៅជាស្រី ពុំដល់ពុំដូចប្រាថ្នា ។ នាងស្តាប់សារ
សព្វាបរ សម្តេចឥន្ទ្រា មានព្រះបន្ទូលប្រាយប្រាប់ ។ នាងនាថអរ
ក្រៃចំណាប់ លើកករថ្វាយជាប់ បង្គំប្រណម្យវន្ទា ។ ព្រះឥន្ទព្រះ
អង្គមេត្តា សែតស្ត្រគាថា ប្រែប្រាណជាព្រាហ្មណ៍បរិសុទ្ធ ។ ហើយ
ជប់ធ្នូសរខ័នរ័ត្ន ប្រែងថ្នាំប្រាកដ ប្រគល់ទៅព្រាហ្មណ៍ធីតា ។
ហើយមានបន្ទូលផ្តាំថា ព្រះខ័នថ្វា ធ្នូសរប្រសើរកន្ទង់ ។ ប្រទះ
សត្រូវយក្សយ័ន្ត ផ្លូវផ្កាញនាយហោង រប្រែងឲសចទិព្វថ្ងៃ ។ បើ
ជួបនឹងព្រះស្វាមី យកប្រេងនេះនៃ លាបសពព្រះអង្គហើយណា ។

រួចរស់ជីវិតឡើងប្រា កជកុំសង្កា បានដូចសេចក្ដីបំណង ៗ នាង
អរសាទរគន្ធ ទទួលយកហោង ហើយទើបសម្ដេចឥន្ទ្រា ៗ ឲ្យពរ
ចៅព្រាហ្មណ៍ជីតា បង្ហាញមាគ៌ា ហើយស្ដេចហោះហោះប្រៀវប្រែ ៗ
ដល់ឋានត្រៃត្រឹង្សនាយនៃ សោយសុខសួស្ដី ក្រៀមក្រួនព្រះទ័យ
សាទរ ៗ ក្រោយនោះចៅព្រាហ្មណ៍ថ្វាយវរ អញ្ជើញសាទរ បង្គំ
ប្រណម្យម្ម៉ា ៗ សៀតខ័នកៅទណ្ឌសរថ្វា ប្រែងចាំទិសថា លេ
លាយាត្រាធាប់ទ្វី ៗ ដម្រង់ទិសទីបូរី ដោយដងព្រឹក្សព្រៃ សង្កេត
សង្កាតតាមបទ ៗ ថ្ងៃយប់ពុំឈប់ពុំឈរ សង្កាត់ចេញចរ ឲ្យឃើញ
ព្រះវៀមជា ៗ ឆ្ងាយសល់ទតយល់សាលា ចៅព្រាហ្មណ៍គិតថា
អញចូលសំណាក់សិននៃ ៗ លំហើយកំសាន្តព្រះទ័យ ចៅព្រាហ្ម
ណ៍ចូលវៃ សំណាក់ក្នុងសាលាឋាន ៗ នឿយណាស់ព្រាហ្មណ៍
ប្រាជ្ញប្រះប្រាណ ក្នុងសាលាឋាន សម្រាន្តលំហើយព្រះអង្គ ៗ ព្រះ
ពាយផាត់ផាយមកត្រង់ ព្រាហ្មណ៍ដួលក់លង់ លុះថ្ងៃទន្ទាបសុរិយា ៗ
កាលណោះមែនមានយក្សា ពីរនាក់អង្គា ឈ្មោះបង្កមួលយក្សយង់ៗ
ប្អូនឈ្មោះនន្ទរកក្រើសក្រឡង់ យក្សព្រៃពីរពង្ស ចិតនៅសាលានោះ
ឯង ៗ ជាទីលំនៅពីព្រេង ព្រឹក្សព្រៃនោះឯង ព្រះបាទព្រៃតសូរអ
សុក ៗ បើកឲ្យយក្សពីរអង្គា ថែចាំរក្សា ជាឋានលំនៅប្រែកតី ៗ
កាលព្រាហ្មណ៍ចូលផ្ទុំនោះនៃ យក្សពីរត្រាច់ព្រៃ លុះដួប ៧ ទិវា ៗ
ស្រេចយក្សវិលវិងយាត្រា ហោះដោយវេហាស៍ មកដល់សាលាឋានចិតៗ

មើលយល់ព្រាហ្មណ៍ផ្ទុំសៀមស្ងាត់ យក្សក្រេវក្រោធក្តាត់ បំណាងសំ-
ពង់ឡក្ស័យ ។ យក្សចូលដល់ស្រែបរិលវៃ ចាក់ព្រាហ្មណ៍ឲ្យក្ស័យ
ឲ្យទោព្រាហ្មណ៍បក្សារក្សាក់ ។ ចាប់ផ្ទួសរ៉េនប្រតិយក្ស ទតយល់
យក្សចាក់ ក្រេវក្រោធពន្ទឹកមហិមា ។ មានព្រះបន្ទូលត្រាស់ថា
វៃហយក្សអសុរ ម្តេចមិនចិត្តធំកន្ទួង ។ ចាក់អញអម្បាញត្រូវខ្ទង់ អេះ
មឹងនេះម្តង សមក្ស័យជីវិតមរណា ។ កម្ពុលយក្សស្តាប់រ៉ាចា
ទេវទឹងមហិមា ថាយើមនុស្សអប្រិយ៍ ។ ម្តេចហ៊ានចូលមកដល់ទី
ណាសាយើងខ្ញុំ ដេកលេងពុំកោតបេស្តា ។ អញខាំក្បាលមិនទំពារ
ឥឡូវនេះណា កុំឲ្យឈាមស្រកដល់ដី ។ កាលណោះទៅព្រាហ្មណ៍
បុទ្ធី ស្តាប់ពាក្យអសុរី ក្រេវក្រោធពន្ទឹកមហិមា ។ កំថ្លែងផ្ទួសរ
បុព្វា យុទ្ធនឹងយក្សា ទាំងពីរជល់ដោរមតេជដៃ ។ ទៅព្រាហ្មណ៍
មានបុទ្ធិក្រែ ថ្លែងផ្កាញអសុរី យក្សសោតទាំងពីរមរណា ។ តេជះ
បុទ្ធិសរថ្មា ពីព្រះឥន្ទ្រា ឥតមានអ្នកណាស្មើបាន ។

## បទកាកគតិ

ទៅព្រាហ្មណ៍ឯកា មែនមានចេស្តា ពន្លឹកក្រើងក្រាន ផ្គលផ្តាច់
ផន្ទា អសុរាសាមាន្យ គង់គិតរំពឹង កន្លងចិត្តចិន្តា ។ ឥឡូវ
យក្សមរណ៍ ដោយតេជធ្នូសរ ក្សិណក្ស័យហើយណា ទិអញចប់
សល់ ក្រែងយល់ក្សត្រា ប្រែងជាំទិសថា ប្រោសប្រស់ព្រះអង្គ ។
ក្រែងខុសពុំបាន ដោយចិត្តបំណាន បំណងយូរលង់ ដៀតអញផ្កាញ

យក្ស អបលក្ខណ៍សូទ្យសុន៍ ប្ដេះគួរអញចង់ ប្រែស់យក្សនេះនៃ ៗ
ឲ្យរស់ជីវិត ដូចដើមប្រាកដ នោះក្សូគាប់ក្រៃ រួចអញតាមក្សត្រ
បរកាត់ព្រៃក្សៃព្រៃ គិតស្រេចព្រាហ្មណ៍វៃ យកថ្នាំផុសថា ៗ ចូលលាបយន៍
យក្ស ទាំងពីរប្រាណក្ងាក់ ក្រោកឡើងម្នីម្នា យង់យល់ព្រាហ្មណ៍
ប្រាជ្ញ គោតក្វាបបេស្ដា ក្រួញក្រាបសិរសា បង្គំប្រតិបត្តិ ៗ យក្សា
កម្ពល ទទួលកក្វាយខ្វល់ លើកបាទនាងក្សត្រ ដាក់លើសិរសា
ស្មាលាទោសថ្វាត់ ហើយសូមប្រណិបត្ន ជាខ្ញុំបាទា ៗ លុះអស់ជីវិត
ជាខ្ញុំបពិត្រ ក្រជាមេ្តចម្ចា ធានាខ្ញុំត្រង់ ស្ដាប់ផងកាជា សូមទ្រង់
មេត្តា ទុកអាយុខ្ញុំ ៗ ក្សណព្រាហ្មណ៍សុរិយង់ យល់យក្សពីរ
ពង្ស ប្រណិបត្នសូមសុំ លាទោសនឹងក្សត្រ- ត្រីវត្នខ្ទត្តម នាង
ថាអញពុំ ដឹងចង់ទោសា ៗ កម្ពលយក្សា ស្ដាប់អញបរវា
ប្រាយប្រាប់ចងណា អញជាក្សត្រី ប្រិមប្រិយសោភា ជាអគ្គជាយា
ព្រះសុវណ្ណហ៊ុន ៗ កិលៀងទាំងប្រាំ រាគយឃ្លាំចាំ ចាក់ព្រះវរ
វង្ស ដាប់ទាំងលំពែង ស្ដេចស្ដេងលុះបង់ ខ្ញុំនាំព្រះអគ្គ ហោះ
ហើរវេហាស៍ ៗ ស្មោះទៅនគរ អយុទ្ធបុរី អញពុំដឹងជា
ព្រះអង្គក្សិណក្ស័យ ប្រល័យជន្មា ឬមួយក្សត្រា រួចរស់ព្រះជន្ម ៗ
អញតាមមកស្មោះ ឈាមបាត់កាលណោះ ពុំដឹងដម្បូន់ ជួបព្រះឥន្ទ្រា
លេលាពីមុន ទល់ទីសុវណ្ណ ឲ្យព្រះគាថា ៗ ប្រែប្រាណជា
ព្រាហ្មណ៍ ទើបអញត្រាច់តាម រកព្រះរាជា ពុំដឹងទីសទី បូរីត្រាមា

អយ្យក្រ្តត្រង់ណា ពិតពុំដឹងឡើយ ៗ កម្ពុលយក្សស្តាប់ ក្សត្រី
ព្រាយប្រាប់ ដឹងដើមហេតុហើយ ទូលថាបពិត្រ កុំក្សត្រត្រាណ-
ត្រើយ ព្រួយព្រះទ័យឡើយ ខ្ញុំនឹងរកជា ៗ ព្រាហ្មណ៍ថាអើបង
គិតដូចនោះហោង អញ្ជើញមហិមា តែបង់ប្រែប្រាណ ឲ្យបានដូចគ្នា
ជាព្រាហ្មណ៍លេលា ដូចដល់ប្តី ៗ បើជាយក្សយល់ យើងនឹង
ចូលទៅក្នុង វត្តនៅជាទី ត្រឹមមនុស្សភិតភ័យ ខ្លាចក្រែអស្រី
ចូលបងគិតទី- មិត្រឲ្យដូចគ្នា ៗ យក្សស្តាប់បន្ទូល ក្សត្រីវិល
ត្រឡប់ព្រមហើយណា ទីមិត្តជាព្រាហ្មណ៍ រូបតាមធីតា សឹងល្អដូចគ្នា
យានយាសចេញផ្ចាត់ ៗ ចូលព្រៃជ្រៅជ្រៃ ឈើឈរជង្គុំ មាន
ម្ហូបស្រឡាត់ ព្រាហ្មណ៍ទាំងពីរនាក់ ត្រាច់តែរកក្សត្រ ដូចឆ្ងាយ
ពេកក្តាត់ ពុំឈប់សម្រាន្ត ៗ ត្រាច់ព្រៃព្រឹក្សា នាងនាថធីតា
នឹងយក្សពីរប្រាណ ព្រួតសព្វសត្វ ស្រឡាត់ស្ងួនឲ្យសាន្ត ខ្វះហើរ
ផាសតានរ ទោកខ្ទុំ ៗ បងអើយបងមើល សត្វអ្វីវាហើរ ទទះ
ស្លាប់ខ្ញុំ កម្ពុលព្រាហ្មណ៍ឆ្លើយ ម្ចាស់អើយមៀមមុំ វាចាប់ខ្ទុំ ខ្ញុំ
ដើមទន្លា ៗ យក្សអើយសត្វអ្វី ខ្ញុំទាំងឈ្មោលញី សិតស្លាបដូច
គ្នា យក្សទូលបពិត្រ ហៅសត្វសារិកា ខ្ញុំដើមក្រសា ទាំងគូនិត្យ
នៅ ៗ វីសត្វអ្វីនោះ វាហើរបំពោះ ខ្ញុំដើមក្រចៅ ឈ្មោះសត្វ
ស-ក ហើរចុះសំលៅ រកឈ្មោលវានៅ លើដើមចម្ប៉ា ៗ នាង
យល់សព្វសត្វ វាហើរប្រាកត ខ្ញុំដើមព្រឹក្សា ខ្ញុញនៅព្រៃពោធ នរនាថ

ថ្ងៃថា ខ្ញុំទំយាត្រា រុករកព្រះបង ៗ កម្ពលយក្សា ទូលទៅធីតា
ថាជិតហើយហោង ម្ចាស់កុំសោយសោក វិយោគឲ្យម៉ង ល្ងាចតិចរំលង
ព្រៃដល់នគរ ៗ នាងប្រាបដាក់ដាត ក្សត្រីទំឃ្មាត ពុំឈប់ពុំឈរ
ស្រេចដល់បុរី ស្រីថ្ងៃបវរ ចូលដល់នគរ ទាំងពីរគ្នា ៗ យន់យល់
សត្វជង ទ្រហឹងគឹងកង ប្រើនក្រែមហិមា ហើយព្រះសុរិយា ល្ងាច
ពន់វេលា ព្រាហ្មណ៍ប្រាជ្ញគិតថា ហៃបងយក្សយង់ៗ ឥឡូវសុរិយា
ល្ងាចហើរហើយណា យើងនឹងឈប់រង់ ដេកនៅសាលា យកគ្រាប្រៀប
ប្រុង ចាំយាមនៅកង យប់ត្រីកាល ៗ លុះព្រឹកសុរិយា រៀងរះ
បុព្វា សម្តេចភូបាល ព្រះសុជនរ័តន៍ ចក្រវត្តិពងា មានព្រះឱង្ការ
ត្រាស់ប្រើសេនា ៗ ឲ្យរៀបប្រដាប់ រៀបមេរុមណ្ឌប ហើយរៀបរាជ
រ័ត្នមាសប្រពៃ ស្តេចក្រែមហិមា ដាក់សុពក្សត្រា ចុះពីរាជស្ថានៗ
ដល់ព្រះរាជរថ ពលផងច្រើនក្តាត់ អូសចេញចាកឋាន ដល់ក្រៅព្រះវាំង
ក្សត្រទាំងពីរប្រាណ សប្បាយប្រមាន ឲ្យអស់ពលផង ៗ ទើប
ព្រាហ្មណ៍ទាំងពីរ លេលាចរលី យល់ជាក់ហើយហោង មានព្រះបន្ទូល
សាស្តូរហៃបង កម្ពលយើងលង ចូលសួរឲ្យជាក់ ៗ ជាខ្មោច
អ្នកណា ឬសពក្សត្រា យើងចូលសំណាក់ ឲ្យដឹងដើមក្តី ក្សត្រី
វរលក្ខណ៍ ជាព្រាហ្មណ៍ពីរនាក់ ចរចូលធាប់ពៃ ៗ ខ្សឹបខ្សៀវ
សួរថា អ្នកអើយយើងជា ព្រាហ្មណ៍នៅក្រុងក្រៃ ស្រុកស្រែចំការ
ពុំដឹងដើមក្តី ស្តេងស្តេចនាមអ្វី គោត្រឡាអីកង ៗ អស់ពល

ស្តែងស្តាប់ ព្រាហ្មណ៍សួរប្រញាប់ ថាអ្នកនេះហាន ជាព្រាហ្មណ៍
ល្អល្អះ ត្របះម៉ត់ម៉ង សើចសួរដើមទង ប្រាយប្រាប់ទៅថា ។
ហៃអ្នកព្រាហ្មណ៍អើយ ក្សត្រាត្រាណត្រើយ នាំសពុត្រា ឈ្មោះ
សុវណ្ណហង្ស វរវង្សថ្លាថ្លៃ គេចាក់ពីណា ស្តេចមកដល់ឋាន ។
ក្សិណក្ស័យព្រះផន្ទ ព្រះបិតាគន់ គិតបុត្រកល្យាណ ស្តេចឲ្យប្រ-
ដាប់ មេរុស្រាប់ស្រេចបាន នាំព្រះសពថ្កាន ដាក់ព្រះមេរុមាស ។
ចូរកុំអ្នកថ្លែង អ្នងដឹងតែឯង កុំប្រាប់គេផ្តាស ក្រែងមានទោសខ្លួន
ថាខ្ញុំកាចខ្លាស អ្នកព្រាហ្មណ៍កុំមាស ប្រាយប្រាប់គេឡើយ ។ ចៅ
ព្រាហ្មណ៍ក្សត្រី ស្តែងស្តាប់សំដី គេប្រាប់ហ្នោះហើយ ស្លុលអន់ទឹក
ដីគាត្រាណត្រើយ ខំទប់ព្រាងើយ ចរចូលទៅថ្វាត់ ។ ចាប់ព្រះពជរថ
ទឹងនៅប្រាកដ ពិតពុំសាសាត់ ឯអស់ពួកផង អឹងកងប្រែនក្តាត់
គើចទុងពជរថ ពុំរួចឡើយណា ។ អស់ចិត្តទទៃ ពុំរួចហើយនៃ
អស្ចារ្យមហិមា ហេតុតែតេជះ តបះបុត្តា ព្រាហ្មណ៍ចាប់រថា ទឹង
នៅនោះនៃ ។ អស់ចាំងសេនា ធ្លល់ធ្លាយមហិមា គយគន់រំពៃ
មើលយល់ព្រាហ្មណ៍ពីរ ចរចេញឆាប់រ៉ៃ ចាប់ពជរថថ្លៃ ទឹងនៅនោះ
ណា ។ មន្ត្រីជាធំ យល់ប្លែកពិតពុំ សៀមហើយម្នីម្នា ចូលជិត
ព្រាហ្មណ៍នៃ ប្រស្រ័យសួរថា អ្នកមកពីណា ល្អល្អះពេកក្តាត់ ។
ហើយអ្នកលេលា ចាប់ព្រែករថា ទឹងនៅប្រាកដ ចូរអ្នកប្រាប់ប្រាយ
និយាយប្ដូរបទ ឲ្យដឹងប្រាកដ សោះយើងសង្កា ។ ចៅព្រាហ្មណ៍

ស្តេចស្តាប់ មន្ត្រីសាសព្វ សាសន៍ទៅថា ហៃអស់មន្ត្រី យើងខ្ញុំ
យាត្រា មកប្រែសកផា ឲ្យរស់ជីវី ។ បើពុំរួចរស់ យើងទទួល
ខុស ទាំងពីរនេះនៃ ឲ្យស្តេចសម្លាប់ ឲ្យស្លាប់ក្សិណក្ស័យ ប្អូនអ្នក
ចាប់វៃ បួលទូលក្សត្រា ។ មន្ត្រីស្តេចស្តាប់ រួសរាន់ប្រញាប់
បួលទូលបំគា បពិត្រព្រះបាទ នរនាថថ្វៃថ្វា មានព្រាហ្មណ៍ពីណា
បួលចាប់ពេវថ ។ ព្រាហ្មណ៍ពីរអង្គ សំរឹលដូចគ្នា រូបកាយបរិសុទ្ធ
ថាបេះអាគម សូមសុំព្រាកផ នឹងប្រែសកផបុត្រ ឲ្យរស់ជីវី ។ បើ
ពុំរួចរស់ ណាខ្ញុំទទួលខុស ឲ្យព្រះភូមី សម្លាប់ក្សិណក្ស័យ នាថ្ងៃនេះខ្ញុំ
សូមព្រះបត្រី ផ្តាបសព្វប្រការ ។

## បទព្រហ្មគីតិ

ព្រះបាទសុធនរ័តន៍ ស្តាប់សាសព្វយល់អស់ការ ត្រីត្រយក្នុង
ព្រះហា ឫទ័យទើបត្រាស់ថាអរគុណ ។ ប្អូនអ្នកចរលេលា បេញ
យាត្រាទៅនាំថ្វាត់ អញ្ជើញព្រាហ្មណ៍បរិស័ទ អញ្ជើញចាំនៅរនេះណា ។
មន្ត្រីស្តាប់ព្រះបាទ រត់ខ្ញុំឃាតដល់ព្រាហ្មណា ថ្វៃងស្ងួចព្រះវាចា
បន្ទូលព្រះបាទបមទៅ ។ អញ្ជើញព្រាហ្មណ៍បួលថ្វាត់ ព្រះមហា
ក្សត្រគង់ចាំនៅ ទន្ទឹងព្រាហ្មណ៍បួលទៅ ស្តេចផ្តល់អស់សាច់អត្ត ។
ព្រាហ្មណ៍ស្តាប់រួចឃាតខ្ញុំ បួលទាំងទ្វីដល់ព្រះបាទ ស្តេចទតយល់
ព្រាហ្មណ៍ស្អាត រូបល្អ ។ ដូចក្សត្រ ។ ស្នាគាង៍រាងរៀវសម បរិត្តៈ
ខ្ញុំកក្រូប្រិមប្រិយ ស្រស់ស្រួលស្រេចល្អមល្អៃ សុភាពកក្រូអគ្គងង៍

ឯក ៗ ទើបស្ដេចបន្ទូលថា ហៃចៅព្រាហ្មណ៍ល្អចំឡែក ត្រ-កាលកប់គាប់ក្អែក ហាក់ស្រីទិព្វទេពសួគ៌ា ៗ អ្នកប្រុសព្រាហ្មណ៍ប្រាជ្ញប្រាយ អ្នកនិយាយទឹងសេនា ទឹងប្រាសប្រស់ប៉ុត្រា ទឹងសិល្បសាស្ត្រមន្តអាគម ៗ ទើងចាំចិសថ ទើបប្រាកដថ្លៃឧត្តម ថាបើព្រាហ្មណ៍សូសម ប្រស់គូនអញស្រស់ផន្ទា ៗ ព្រះគុណអ្នកជូនក្រៃ បែងប៉ុឲ្យអ្នកណា កស្ត្រដេកក្នុងភាព សេះដំរីបរិពារពល ៗ

មានតទៅទី ២ទៀត

ពិរោះហើយកំសត់ផង

| | | | |
|---|---|---|---|
| | ...បហោះ | ថ្លៃ | ៨៛០០ |
| ១៨– | សរសេរតាមសូត្រ ពន្យល់ | ,, | ២០៛០០ |
| ១៩– | ប្រជុំសិក្ខាបទក្នុងបាតិមោក្ខ | ,, | ១០៛០០ |
| ២០– | វេយ្យាករណបទីប | ,, | — |
| ២១– | ប្រស្នាកច្ចាយនូបត្ថម្ភកៈ ទី ២ | ,, | ២០៛០០ |
| ២២– | ច្បាប់រដ្ឋធម្មនុញ្ញ | ,, | ១០៛០០ |
| ២៣– | ជីវណកថា | ,, | ២៛០០ |
| ២៤– | អនុពុទ្ធប្រវត្តិ | ,, | ២២៛០០ |
| ២៥– | ទុល្លភធម៌ | ,, | ៧៛០០ |
| ២៦– | រឿងម៉ាកប៉ាយុនកែវ ទី ១-២-៣ | ,, | ៩៛០០ |
| ២៧– | អន្តរធានកថា | ,, | ១០៛០០ |
| ២៨– | សំយោគវិធាន | ,, | ១៣៛០០ |
| ២៩– | ៣ ភាសា ខ្មែរ-ចិន-យួន ទី ១ | ,, | ១០៛០០ |
| ៣០– | រឿងបុទ្ធិវង្ស ទី ១ ២ | ,, | ៨៛០០០ |
| ៣១– | រឿងលិនថោង | ,, | |
| ៣២– | រឿងវរនេត្រវរនុជ ទី ១ | ,, | ១០៛០០ |
| ៣៣– | រឿងសុវណ្ណហុង | ,, | ១០៛០០ |
| ៣៤– | អរិយមគ្គាធិប្បាយ | ,, | |
| ៣៥– | មហោសថ | ,, | ១០៛០០ |
| ៣៦– | រឿងផាភ | ,, | |